# ធាតុកថា

ព្រះបាឡាត់ឃោសធាត

## ហែម-ចៀវ

(ជោតញ្ញាណោ)

អាចារ្យ

សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ប្រែរៀបរៀង

INSTITUT BOUDDHIQUE

ភ្នំពេញ

ព.ស. ២៥០៩

# អារម្ភកថា

សៀវភៅនេះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បម្រុងនឹងរៀបរៀង ដោយព្រះអង្គលោក មានសេចក្ដីអារាធនារបស់លោកគ្រូចៅអធិការ **ឱក-ឱម** ប៉ុន្តែលោកមានការងារច្រើនលើសលប់ពេក រកឱកាសនឹងឆ្លៀតធ្វើឱ្យហើយទាន់ពេលមិនបាន ក៏លោកដាក់ភារៈប្រគល់ឱ្យខ្ញុំធ្វើ ខ្ញុំក៏ទទួលរៀបរៀងតាមកម្លាំងសតិបញ្ញារបស់ខ្លួន ។

សៀវភៅនេះ ខ្ញុំកំណត់ឱ្យឈ្មោះ **ទានកថា** ចែកជា ៤ ពួក ដើម្បីឱ្យងាយសង្កេតដល់សាធុជនអ្នកមើល

ទី១ ឈ្មោះ **ទានប្បកាសនកថា** និយាយប្រកាសបើកលំអានអំពីការឱ្យទាន,

ទី២ ឈ្មោះ **ទានវិភជនកថា** និយាយអំពីចំណែកឈ្មោះទាន,

ទី៣ ឈ្មោះ **ទានលក្ខណកថា** និយាយអំពីលក្ខណៈ ឬ របៀបឱ្យទាន,

ទី៤ ឈ្មោះ **ទានានិសង្សកថា** និយាយអំពីអានិសង្សរបស់ទាន ។

កាលដែលចាប់ផ្ដើមរៀបរៀងធម៌នេះ មកប្រទះលើកាលដែលខ្ញុំកំពុងមានកិច្ចរវល់ខ្វាន់ៗ រកវេលានឹងធ្វើឱ្យហើយរហ័សមិនបាន ខ្ញុំក៏រំលែកឱ្យលោកអាចារ្យ **ហាយ** ក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ឱ្យលោកជួយរៀបរៀងត្រង់កថាទី១ និង កថាទី៤ ដើម្បីឱ្យបានសម្រេចឆាប់រហ័សទាន់ពេល ។

ឯគម្ពីរដែលខ្ញុំដកស្រង់យកធម៌ មករៀបរៀងទុកក្នុងសៀវភៅនេះ គឺ គម្ពីរមង្គលត្ថទីបនី ១ អង្គុត្តរនិកាយ ព្រមទាំងអដ្ឋកថា ១ មជ្ឈិមនិកាយ ១ ខន្ធកវិនយមហាវគ្គ ១ យោជនាដីកាវិន័យ ១ ទុតិយសមន្តប្បាសាទិកាអដ្ឋកថា ១ ទាំងសេចក្ដី

សម្រាយដែលលោកអ្នកប្រាជ្ញ បានប្រែរៀបរៀងទុករួចមកហើយខ្លះ យកមករួបរួម ។ លុះខ្ញុំរៀបរៀងរួចស្រេចហើយ ទើបយកទៅប្រគេនព្រះតេជគុណព្រះពុទ្ធឃោសាចារ្យ សូមឱ្យលោកផ្ទៀងផ្ទាត់ លោកក៏ទទួលផ្ទៀងឱ្យដោយសព្វគ្រប់ ឃើញថាត្រឹមត្រូវហើយ ។

ដោយកម្លាំងព្យាយាម ដែលខ្ញុំរៀបរៀង **ធានកថា** នេះ សូមឱ្យព្រះពុទ្ធសាសនារុងរឿងអស់កាលជានិច្ច ! ទាំងពួកពុទ្ធ-បរស័ទ ដែលបានសិក្សានិងប្រតិបត្តិតាម ក៏សូមឱ្យបរិបូណ៌-ដោយសេចក្តីចម្រើនសព្វៗ វេលា ! ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ថ្ងៃច័ន្ទ ៣ កើត ខែអស្សុជ ឆ្នាំថោះ ឯកស័ក ព.ស. ២៤៨២

ត្រូវនឹងថ្ងៃ ១៦ តុលា ឆ្នាំ១៩៣៩ ។

ព្រះបាឡាត់ឃោសនាគ ហែម ចៀវ

អាចារ្យសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

# ទានប្បកាសនកថា

*នមត្ថុ រតនត្តយស្ស*

សត្វទាំងឡាយក្នុងលោកនេះ កាលបើពោលតាមប្រភេទនៃពួកសត្វ មានច្រើនពួកច្រើនឈ្មោះជាអនេក តែបើពោលដោយរួបរួម បានដល់សត្វតែ ១ ពួក ដែលមានជីវិតជាទីស្រឡាញ់តែប៉ុណ្ណោះ ពួកសត្វទាំងអស់សុទ្ធតែមានសេចក្តីសុខទុក្ខជាប់ទាក់ទងដោយរាងកាយ ឬ ថាមានរាងកាយជាទីអាស្រ័យនៅនៃសេចក្តីសុខទុក្ខ ដូចគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស ។ ជីវិតដែលតាំងនៅបានក៏ព្រោះអាស្រ័យរាងកាយ, ការគ្រប់គ្រងចិញ្ចឹមរាងកាយដោយអាហារផ្សេងៗ ក៏ឈ្មោះថាគ្រប់គ្រងជីវិត ។ ការរក្សាជីវិតរបស់មនុស្សទាំងអស់ជាភារៈយ៉ាងធ្ងន់បំផុត, សាច់ ឈាម ស្បែក សរសៃ ពណ៌សម្បុរដែលចម្រើនស្រស់បស់ឡើងបានក៏ព្រោះអាស្រ័យអាហារ, កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចម្រើនជាប់តទៅក៏ឈប់ចម្រើន, រាងកាយទាំងមូលក៏ស្វិតស្រពោនថយចុះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅ, ទាំងជីវិតសោតក៏តាំងនៅបានដោយក្រ ។ អាហារជារបស់សំខាន់សម្រាប់បម្រុងជីវិតឱ្យប្រព្រឹត្តទៅ សមដូចបាលីថា *សព្វេ សត្តា អាហារដ្ឋិតិកា* “ពួកសត្វរាល់រូបមានជីវិតតាំងនៅបានព្រោះអាហារ” ។ វត្ថុដទៃក្រៅអំពីអាហារនោះទៀត ជនជាតិមនុស្សត្រូវមានលំនៅសម្រាប់ជាទីជ្រកកោនសំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែរោគក្នុងគ្រាដែលត្រូវការ, វត្ថុអម្បាលនេះ សុទ្ធតែជារបស់សម្រាប់ឧបត្ថម្ភទប់ទល់ជីវិតដោយពិត បើប្រាសចាករបស់ណាមួយ ជីវិតរមែងតាំងនៅបានដោយលំបាក ។ ជនជាតិមនុស្សលុះតែមានចំណេះវិជ្ជា ឬកម្លាំងកាយកម្លាំងបញ្ញាបរិបូណ៌ ទើបអាចស្វែងរកអាហារបានបរិភោគ រកទីអាស្រ័យនៅនឹងគ្រឿងប្រើប្រាស់សម្រាប់ជួយជីវិតបានគ្រប់គ្រាន់ល្អ ។ ចំណែកមនុស្សដែលគ្មានចំណេះវិជ្ជា ខ្សោយកម្លាំង ឬឥតគុណសម្បត្តិណាមួយក្នុងខ្លួន ក៏មិនអាចរក្សាជីវិតរាងកាយ ឱ្យរស់នៅតាមទំនើងខ្លួនឯងបានឡើយ, មនុស្សបែបនេះ ត្រូវអាស្រ័យពឹងផ្អែកនឹងអ្នក

Websites: WatKhemaraRatanaram.org or WatKhmers.org

ដទៃ ឱ្យគេជួយចិញ្ចឹមជីវិតរបស់ខ្លួនជាដរាប គឺឱ្យជួយប្រាប់ឧបាយក្នុងការចិញ្ចឹមជីវិត, ការរក្សារាងកាយ និងការរក្សាចិត្តឱ្យតាំងនៅដោយល្អ, ព្រោះថាមនុស្សទាំងអស់ក្នុងលោករមែងមានវាសនា ឬ គុណសម្បត្តិនិងកម្លាំងផ្សេងៗគ្នា, ចំណែកខាងមនុស្សដែលខ្សត់ខ្សោយវាសនា និង គុណសម្បត្តិ ឬខ្សោយកម្លាំងកាយ និង សម្ងំនៅតាមទំនើងខ្លួនឯងមិនបាន ត្រូវធ្វើសមាគម គប់រកមនុស្សដែលសម្បូណ៌វាសនា និង គុណសម្បត្តិ ឬកម្លាំងកាយ ឱ្យជួយណែនាំបង្ហាត់បង្រៀន ជួយជ្រោមជ្រែងដោយទ្រព្យរបស់ ឬ ភោជនាហារសម្រាប់ចិញ្ចឹមជីវិត ។ មនុស្សដែលមានវាសនា និង គុណសម្បត្តិខ្ពង់ខ្ពស់ ក៏ត្រូវតែទទួលអភិបាលរក្សាមនុស្សដែលនៅតូចទន់ខ្ចី ឬ ថោកទាបជាងខ្លួនដោយកិច្ចប្រៀនប្រដៅ និង ទ្រព្យសម្បត្តិជាដើមទុន ឬ អាហារសម្រាប់បរិភោគរាល់ថ្ងៃជាដរាប ដូចមាតាបិតាជាប្រធាននៃបុត្តធីតា ។ ការឱ្យអាហារ ឬ គ្រឿងប្រើប្រាស់គ្រប់យ៉ាង នេះជាកល្យាណប្បវេណី, ជាទំនៀមមួយដ៏វិសេស ជាប់មកតាំងអំពី

Websites: WatKhemaraRatanaram.org or WatKhmers.org

មុនពុទ្ធកាល តាមបាលីលោកហៅថា **ទាន** ប្រែថា ការឱ្យ ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានចិត្តអាណិតទោរទន់ទៅរកមនុស្សសត្វដទៃ ហើយបានឱ្យគ្រឿងបរិភោគដោយសេចក្តីអា-ណិតតែម្យ៉ាង មិនអាស្រ័យយកកម្លាំងប្រើប្រាស់ ការឱ្យទានដូច្នេះហៅថា **ករុណាទាន** ។ បុគ្គលខ្លះយល់ច្បាស់ក្នុងគុណូបការៈ ឬគុណសម្បត្តិណាមួយរបស់លោកអ្នកមានគុណមានមាតាបិតាគ្រូអាចារ្យឬលោកអ្នកទ្រទ្រង់នូវគុណ មានសីល-គុណជាដើម ក៏ធ្វើទានចំពោះលោកអ្នកមានគុណនោះ ការឱ្យទានដូច្នេះ ហៅថា **បូជាទាន** ឬ **បដិការទាន** ។ មនុស្សពួកខ្លះជាអ្នកមានចិត្តធូរទូលាយ ចង់ឱ្យប្រយោជន៍ ឱ្យសេចក្តី-សុខ សេចក្តីចម្រើនដល់អ្នកដទៃ ដែលជាញាតិសាលោហិត ឬមិត្តសំឡាញ់ ឬក៏ ជាមនុស្សរួមជាតិជាមួយគ្នា ដែលល្មមទទួលអំណោយការសង្គ្រោះបាន ហើយចែកទ្រព្យសម្បត្តិជាដើមទុនក្តី គ្រឿងបរិភោគគ្រឿងប្រើប្រាស់ក្តី ដើម្បីទំនុកបម្រុងជួយជាកម្លាំងសង្គ្រោះ ឱ្យកើតប្រយោជន៍ស្មើមុខគ្នាឡើង, ការឱ្យទានដូច្នេះ ហៅថា **អនុគ្គហទាន** ឬ **សង្គហទាន** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងឡើង ក្នុងលោកហើយ ព្រះអង្គបានស្រាវជ្រាវសំដែងពន្យល់ពុទ្ធបរិស័ទ អំពីទាន និង ចាគៈ ដោយន័យច្រើនជាអនេក បានទាំងទ្រង់ប្រៀនប្រដៅ វិធី ក្នុងការបរិច្ចាគទាន ដោយសព្វគ្រប់ សឹងមានប្រាកដ មកក្នុង ស្ថានធម៌ផ្សេងៗ គឺមានមក ក្នុងអនុបុព្វីកថាខ្លះ បារមី ធម៌ខ្លះ ក្នុងសប្បុរិសប្បញ្ញត្តិខ្លះ ក្នុងបុញ្ញកិរិយាវត្ថុខ្លះ ក្នុង ទសពិធរាជធម៌ខ្លះ ក្នុងអរិយទ្រព្យខ្លះ ក្នុងអធិដ្ឋានធម៌ខ្លះ ក្នុង សង្គហធម៌ខ្លះ ក្នុងសម្បរាយិកត្ថធម៌ខ្លះ ក្នុងឧបនិស្សយធម៌ ខ្លះ ។ គុណសម្បត្តិគឺការបំពេញទាននេះ ចាត់ជាមង្គលមួយ ដ៏ប្រសើររបស់សប្បុរស ។

ភោគសម្ប័ទទាំងអស់ក្នុងលោកនេះ រមែងកើតទៅជាទោស ក៏មាន ទៅជាគុណក៏មាន ។ ភោគសម្ប័ទណាដែលនៅ ក្នុង ដៃរបស់មនុស្សល្ងង់ខ្លៅ ជាអ្នកមិនយល់ប្រយោជន៍ ដ៏ធំទូលាយ ក្នុងកាលឥឡូវនេះនឹងកាលខាងមុខ ទ្រព្យសម្បត្តិនោះ នឹង ត្រឡប់ទៅជាទោសដល់ខ្លួនជាម្ចាស់វិញដោយពិត ជួនកាលក៏

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រាន់តែជារបស់កណ្តាលៗ មិនសម្រេចប្រយោជន៍ធំទូលាយត ទៅទៀតក៏មាន ដូចអ្នកមានប្រទីបសម្រាប់អុជបំភ្លឺ តែបើ ម្ចាស់មិនអុជបំភ្លឺទេ ក៏មិនមានប្រយោជន៍អ្វី អំពីប្រទីបនោះ ឡើយ ។

ភោគសម្ប័ទណា ដែលនៅក្នុងដៃរបស់មនុស្ស អ្នកចេះ ដឹងជាអ្នកយល់ប្រយោជន៍ដ៏ធំទូលាយ ទ្រព្យសម្បត្តិនោះ នឹង ត្រឡប់ទៅជាគុណដល់ខ្លួនជាម្ចាស់វិញជាប្រកដ ។ ឯទ្រព្យ សម្បត្តិដែលថាជាគុណ ឬ ជាប្រយោជន៍នោះ គឺសម្រាប់ចាយ វាយទៅចិញ្ចឹមខ្លួន ទំនុកបម្រុងមាតាបិតាគ្រូអាចារ្យ នឹងអន្តោ-ជនពាហិរជនគឺបុត្តភរិយាទាសកម្មករ ធ្វើទក្ខិណាទានចំពោះ ភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនា ដើម្បីជាបុញ្ញនិធិរបស់ខ្លួន, ធ្វើពលី ៥ យ៉ាងមាន ញាតិពលីជាដើម ។ ការប្រើប្រាស់ទ្រព្យ សម្បត្តិបែបនេះ ឈ្មោះថា ពង្រីកឬបណ្តុះទ្រព្យសម្បត្តិឱ្យបាន ទៅជាគុណជាប្រយោជន៍ ចម្រើនរុងរឿងធំទូលាយ ទាំងឥធលោក និងបរលោក ។ មួយទៀត ជនណាជាគ្រហស្ថមានប្រាជ្ញា

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រប់គ្រងផ្ទះ កាលបើបានលៃលកទ្រព្យធនឱ្យទានទុកជាកំណប់ ជននោះឈ្មោះថា បានជញ្ជូនទ្រព្យសម្បត្តិ ទុកដាក់ឱ្យផុតចាក សេចក្តីអន្តរាយដើម្បីជាប្រយោជន៍តទៅ សមដូចព្រះពុទ្ធភាសិតថាៈ

**អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ**

**តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ**

**ឯវមា ទិត្តកោ លោកោ ជរាយ មរណេន**

**ច**

**នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីកតំ**

(សេចក្តីថា) កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះ តែងជញ្ជូនទ្រព្យសម្បត្តិ មានភាជនៈ (ជាដើម) ចេញពីផ្ទះ ទ្រព្យណាដែលគេប្រញាប់ជញ្ជូនចេញផុត ភ្លើងឆេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេតទៅ យ៉ាងណាមិញ, សត្វលោកដែលត្រូវភ្លើគឺជរានិងមរណៈ ឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឱ្យផុតអំពីផ្ទះ គឺរាងកាយដោយការឱ្យទាន ព្រោះថាទាន ដែលគេឱ្យហើយនោះឯងឈ្មោះថាបានជញ្ជូនទ្រព្យទុកដោយល្អ មិនឱ្យភ្លើងឆេះបាន ក៏យ៉ាងនោះដែរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីនេះបំភ្លឺឱ្យឃើញថា កាលបើផ្ទះ គឺរាងកាយត្រូវភ្លើងគឺជរានិងមរណៈ ឆាបឆេះ ទ្រព្យសម្បត្តិ ដែលនៅក្នុងកំ-ណាន់របស់មច្ឆរិយៈ ដែលគេមិនបានប្រញាប់ជញ្ជូនយកចេញដោយការបំពេញទានទេ ក៏មុខជានឹងត្រូវភ្លើងជរា និង មរណៈឆេះខ្ទេចខ្ទីជាមួយនឹងរាងកាយ ទៅជារបស់ឥតប្រយោជន៍មិន-ខាន ។ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធទ្រង់សំដែងពន្យល់អំពី **ទានៈ** និង **ចាគៈ** ជារឿយៗ ដើម្បីឱ្យកើតប្រយោជន៍ដ៏ធំទូលាយអំពីទ្រព្យសម្បត្តិនោះៗ ដូចសេចក្តីដែលបានសំដែងមកនេះឯង ។ លំដាប់ពីនេះនឹងពោលអំពីពាក្យថា **ទានៈ** និង **ចាគៈ** ដោយសង្ខេប ។ ពាក្យទាំងពីរនេះ បើសំដៅយកសេចក្តី ឃើញប្រាកដថា ផ្សេងៗគ្នា តែបើពោលតាមលក្ខណៈ ក៏ស្រដៀងៗគ្នា, តាមសេចក្តីអធិប្បាយ ចំពោះពាក្យថា **ទានៈ** មានន័យ ៤ យ៉ាង ដូចសេចក្តីដែលត្រូវសំដែងតទៅនេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

១- *ទាន:* ការឱ្យវត្ថុណាមួយដែលនៅជាប់ជំពាក់ដោយមច្ឆរិយៈ ឬឱ្យដោយស្ទាក់ស្ទើរមិនជ្រះស្រឡះចាកមច្ឆរិយៈ ឬក៏ឱ្យតាមទំនៀមត្រកូលរបស់គេ មិនមែនជាកិច្ចអស្ចារ្យចម្លែកជាងត្រកូលដែលធ្លាប់ធ្វើមកប៉ុន្មាន ។

២- *ទាន:* ការឱ្យដែលជាប់ដោយតណ្ហា គឺបុគ្គលអ្នកឱ្យទាន ប្រាថ្នាយកសិរីសួស្តី និង ផលប្រយោជន៍មកខ្លួនវិញចំពោះសាមិសសុខក្នុងភពនេះឬភពមុខ ។

៣ -*ទាន:* ការឱ្យមិនសមគួរ គឺបុគ្គលណាមានទ្រព្យសម្បត្តិច្រើន មានវត្ថុដ៏ថ្លៃថ្លាច្រើន លុះត្រូវការចាត់ចែងទានក៏ចាត់ចែងដោយរលីបរលោបស្តួចស្តើង និងវត្ថុដ៏ថោកទាបតាមធម្មតា, **ទាន** របស់បុគ្គលនោះ ឈ្មោះថាជាទានមិនសមតាមស័ក្តិ តាមកម្លាំងនៃទ្រព្យសម្បត្តិដែលខ្លួនមាន ។

៤- *ទាន:* ការឱ្យចំពោះមុខបដិគ្គាហក, អ្នកទទួលផ្ទាល់ដែលជាបុគ្គលខ្សត់ខ្សោយ ដោយគុណធម៌ និងទ្រព្យសម្បត្តិ

ឬខ្ពង់ខ្ពស់ដោយគុណធម៌, នេះជាសេចក្តីអធិប្បាយរបស់ពាក្យថា **ឆានៈ** ។

ចំណែកខាង **ចាគៈ** ក៏មានសេចក្តីអធិប្បាយចែកចេញជាន័យ ៤- យ៉ាងគឺ

១- *ចាគៈ* ការលះវត្ថុណាមួយចំពោះបដិគ្គាហកៈ ដើម្បីលះបង់ឬសង្កត់សង្កិននូវលោភៈ និងមច្ឆរិយៈ ឱ្យស្រាលស្តើងចាកសន្តាន គឺចំណាយទ្រព្យធនដើម្បីទុកជាអលង្ការ ឬជាកល្យាណវត្តរបស់ចិត្ត មិនបណ្តោយឱ្យចិត្តជ្រលក់ជាប់នៅក្នុងកិលេស ។

២- *ចាគៈ* ការលះឱ្យ ដែលមិនជាប់ជំពាក់ដោយតណ្ហា គឺឱ្យដោយបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើចិត្តឱ្យបរិសុទ្ធ បើកឱកាសឱ្យបញ្ញារបស់ខ្លួន មានកម្លាំងលូតលាស់ចំរើនឡើងផង ដើម្បីប្រយោជន៍ និង សេចក្តីសុខថ្កុំថ្កើងជាតម្រាប់ដល់យុវ-ជនជាន់ក្រោយផង ដូចយ៉ាងការចំណាយទ្រព្យសម្បត្តិទំនុក

Websites: WatKhemaraRatanaram.org or WatKhmers.org

បម្រុងព្រះពុទ្ធសាសនា កសាងសេនាសនៈ លើកថ្នល់ សង់ស្ពាន ជីកអណ្តូងទឹក សង់សាលាបម្រុងការសិក្សាឬសាលាសំណាក់ទុកសម្រាប់ជាសាធារណៈ មិនបានចំពោះបដិគ្គាហកៈ ។

*៣- ចាគៈ* ការលះឱ្យវត្ថុដ៏ច្រើនក្រៃលែង ឬខ្ពង់ខ្ពស់លើសវិស័យរបស់មនុស្សសាមញ្ញក្នុងលោកគួរឱ្យស្ញើច ដែលរាប់ថា ជាការបរិច្ចាគរបស់ព្រះពោធិសត្វ ។

*៤- ចាគៈ* ការលះកាត់អាល័យក្នុងជីវិត និងសេចក្តីសុខក្នុងទ្រព្យសម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្វះស្វែងរកឧបាយជួយជ្រោមជ្រែងមនុស្សក្នុងលោក ឬលះបង់ទ្រព្យសម្បត្តិដើម្បីរោយរាយចែកចាយឱ្យទៅជាប្រយោជន៍ ផ្តល់សេចក្តីសុខសេចក្តីចំរើនរុងរឿងដល់មហាជន ទុកជាកេរ្តិ៍ដំណែលតទៅ ។

ពាក្យថា **ទានៈ** និង **ចាគៈ** មានសេចក្តីផ្សេងគ្នាដូចពណ៌នាមកនេះឯង ។ កាលបើសង្កេតមើលតាមដំណើរ

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីក្នុងន័យទាំងនោះគង់ឃើញច្បាស់ថា **ចាគៈ** មានកម្លាំងជាង **ទានៈ** ឬថា ជាធម៌ខ្ពង់ខ្ពស់ផ្សាយរស្មីរុងរឿងលេចសេចក្ដីទូលាយល្អជាង **ចាគៈ** ។ មួយទៀត **ទានៈ** និង **ចាគៈ** នេះបើពោលតាមលក្ខណៈ រួបរួម ក៏គឺការឱ្យ ការចែករំលែកទ្រព្យសម្បត្តិចំពោះសត្វឬបុគ្គលដទៃប៉ុណ្ណោះឯង, តែបើនិយាយតាមហេតុផលវិញ **ទានៈ** ជាឈ្មោះបរិក្ខារវត្ថុ ដែលគេត្រូវឱ្យ, **ចាគៈ** ជាឈ្មោះចេតនា ដែលជាតួចេតសិកសម្រាប់លះ, **ទានៈ** ចាត់ជាផល, **ចាគៈ** ចាត់ជាហេតុ, អាស្រ័យគ្នាដូចដួងព្រះអាទិត្យនិងពន្លឺរស្មីនៃព្រះអាទិត្យ ។ មួយវិញទៀត **ទានៈ** ដូចជាផ្លែផ្កាដែលលេចចេញចាកដើមឬទង, **ចាគៈ** ដូចជាដើមឬទងនៃរុក្ខជាតិវល្លិ៍ជាតិ ជាបច្ច័យឱ្យកើតផ្លែផ្កា ឬថា **ចាគៈ** ទុកដូចជាដើមពូជមុនដំបូង, **ទានៈ** ទុកដូចជាផ្លែផ្កា ដែលកើតអំពីពូជខាងដើម ដូច្នេះវិញក៏បាន ។

ចប់ទានប្បកាសនកថាតែប៉ុណ្ណោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ការឱ្យទាន ជាបវេណីកិច្ចដ៏ប្រសើររបស់កល្យាណជន ជាចរិយាដ៏វិសេសរបស់បណ្ឌិតទាំងឡាយ មានពោធិសត្តជាដើម ដែលលោកតែងតែបំពេញទុក ជាឧបនិស្ស័យរៀងរាល់ជាតិមិនដែលរំលង ។

កម្រៃនៃការឱ្យទាននេះ រមែងនាំបណ្តាលឱ្យសម្រេចប្រ-យោជន៍ គឺសេចក្តីល្អ សេចក្តីសុខ និងសេចក្តីចម្រើន ដល់បុគ្គលអ្នកធ្វើនោះជាច្រើនប្រការ ។

ធម្មទេសនា ដែលព្រះលោកនាថទ្រង់ត្រាស់សំដែងអំពីទាននោះ មានច្រើនជាអនេក ហួសវិស័យនឹងពណ៌នាឱ្យសព្វគ្រប់បាន តែបើកំណត់ឈ្មោះតាមប្រភេទ ដែលផ្សេងគ្នាដោយចេតនា និង ទេយ្យវត្ថុ មាន ៣យ៉ាងគឺ

១- *ចាគចេតនា ទានំ* ចេតនា ដែលលះទេយ្យវត្ថុឱ្យដល់បុគ្គលដទៃ ឈ្មោះថា **ទាន**,

Websites: WatKhemaraRatanaram.org or WatKhmers.org

២- *វិរតិ ទានំ* ចេតនា ដែលវៀរលេងចាកអំពើអា-ក្រក់មានវៀរចាកបាណាតិបាតជាដើម ឈ្មោះថា **ទាន**,

៣- *ទេយ្យធម្មោ ទានំ* ទេយ្យធម៌ គឺវត្ថុដែលគេត្រូវលះឱ្យដល់បុគ្គលដទៃ ឈ្មោះថា **ទាន** ។

បណ្ដាទានទាំង ៣ យ៉ាងនេះ លើកវិរតិទាន ចេញមិនអធិប្បាយក្នុងទីនេះទេ ព្រោះលោកចាត់ជាអភយទាន បានដល់ការកាន់សីល ៥ ឯណោះដោយឡែក ឯចាគចេតនាទាន និងទេយ្យធម្មទាន ទាំងពីរនេះ ពិតជាមានឈ្មោះផ្សេងគ្នាតាមប្រ-ភេទមែន ប៉ុន្តែជាធម្មជាតមិនអាចនឹងញុំាងកុសលឱ្យសម្រេចបានដោយឡែកពីគ្នាឡើយ ព្រោះថា បើបុគ្គលមានតែចេតនាបម្រុងលះឱ្យ តែគ្មានទេយ្យវត្ថុនឹងលះឱ្យ ក៏ធ្វើជាទានមិនកើត ឬមានទេយ្យវត្ថុល្មមលះឱ្យដែរ តែគ្មានចេតនាសម្រាប់លះឱ្យ ក៏ធ្វើឱ្យកើតជាទាន មិនបាន, លុះតែមាន ចេតនា ទេយ្យវត្ថុព្រមគ្នាទាំងពីរ ទើបបុគ្គលធ្វើឱ្យសម្រេចកើតទៅជា **ទាន** ឡើងបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥឡូវនេះ នឹងលើកយកទានពីរប្រការ ដែលមានមកក្នុងគម្ពីរអង្គុត្តរនិកាយទុកនិបាត មករៀបរៀងទុកជាគោលដើមតាមលំអានពុទ្ធភាសិតថា ទ្វេមានិ ភិក្ខវេ ទានានិ ។ កតមានិ ទ្វេ ? អាមិសទានញ្ច ធម្មទានញ្ច ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។ (ប្រែថា) ម្នាលភិក្ខុទាំងឡាយ ទានមានពីរប្រការ ទានទាំងពីរប្រការតើដូចម្ដេចខ្លះ? (ទានទាំងពីរប្រការនោះ) គឺ

១-*អាមិសទាន* ការឱ្យអាមិសៈ ជាទាន,

២-*ធម្មទានំ* ការឱ្យធម៌ជាទាន ។

ម្នាលភិក្ខុទាំងឡាយ, បណ្ដាទានទាំងពីរប្រការនេះ ធម្មទានជាទានប្រសើរជាងអាមិសទាន ។

## អាមិសទាន

ទាយកទាំងឡាយ ដែលប្រកបដោយសទ្ធា បានលះទេយ្យវត្ថុគឺបច្ច័យ ៤ យ៉ាង និងទានវត្ថុ១០យ៉ាង ឱ្យដល់ស្មូមទាំងពួងហៅថា **អាមិសទាន** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## *បច្ច័យ ៤ យ៉ាងនោះគឺ*

១- *ចីវរប្បច្ច័យ* ចីវរ មានស្បង់ ចីពរ ដង្ឃ្សាដី ជាដើម,

២- *បិណ្ឌបាតប្បច្ច័យ* ភោជនាហារ មានបាយ ជាដើម,

៣- *សេនាសនប្បច្ច័យ* ទីសម្រាប់ដេក អង្គុយ មានកុដិ សាលា ជាដើម,

៤- *គិលានភេសជ្ជប្បច្ច័យ* ថ្នាំជាបច្ច័យសម្រាប់ រក្សាជំងឺ មានថ្នាំត្រាំដោយទឹកមូត្រជាដើម ។

## *ទានវត្ថុ ១០ យ៉ាងនោះគឺ*

១- *អន្នំ* គ្រឿងបរិភោគគឺបង្អែមឬចំអាបគ្រប់មុខ,

២- *បានំ* ទឹក ៨ ប្រការ មានទឹកដែលគេធ្វើដោយផ្លែ ស្វាយជាដើម,

Websites: WatKhemaraRatanaram.org or WatKhmers.org

៣- *វត្ថំ* សំពត់ស្លៀកនិងសំពត់ដណ្តប់ជាដើម

៤- *យានំ* យានដែលញ៉ាំងដំណើរឱ្យសម្រេច មានរថជាដើម មានស្បែកជើងជាទីបំផុត,

៥- *មាលា* ផ្កាឈើគ្រប់យ៉ាង ដែលគេក្រងស្រេចហើយ ឬមិនទាន់ក្រង,

៦- *គន្ធំ* គ្រឿងក្រអូប ដែលជាគន្ធជាតមានក្លិនទាំងអស់ និងគ្រឿងផ្សែផ្សំដល់គ្រឿងក្រអូប ដែលគេកិនក្តី មិនបានកិនក្តី,

៧- *វិលេបនំ* គ្រឿងលាប គឺវត្ថុសម្រាប់លាបស្បែកខាងក្រៅ ឱ្យគួរជាទីត្រេកអរ និងជាទីពេញចិត្ត,

៨- *សយនំ* ទីដេក កន្លែងសម្រាប់ដេកអង្គុយ មានគ្រែ តាំង និងចៀមព្រំជាដើម,

៩- *អាវសថំ* ទីនៅ គឺគេហដ្ឋានជាទីនៅឬជ្រកកោន

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្រាប់ការពារនូវសេចក្ដីអន្តរាយ សេចក្ដីលំបាក មានខ្យល់និងកម្ដៅថ្ងៃជាដើម,

១០- *បទីបេយ្យំ* ប្រទីបនិងគ្រឿងប្រទីប វត្ថុសម្រាប់ទំនុកបម្រុងដល់ប្រទីប មានអំបែង និងប្រឆេះ គោមចង្កៀងជាដើម ។

**អាមិសទាននេះ** ព្រះសម្មាសម្ពុទ្ធជាធម្មស្សាមី ទ្រង់ត្រាស់សំដែងញែកឈ្មោះតាមលក្ខណៈ ឬកិច្ចរបស់ទាននោះមានច្រើនប្រការ បើនឹងស្រូតរូតស្រង់យកទាន ឱ្យបានច្រើនមករៀបរៀងក្នុងទីនេះក៏បាន ប៉ុន្តែពេលមិនល្មម, ហេតុដូច្នេះ នឹងលើកយកតែ **បាដិបុគ្គលិទាន ១ សង្ឃគតាទក្ខិណាទាន ១ សប្បុរិសទាន ១ អសប្បុរិសទាន ១ អសម្មតទាន ១ កាលទាន ១** ទាំង ៦ ឈ្មោះនេះ មករៀបរៀងក្នុងទីនេះ ព្រោះទានប៉ុណ្ណេះទុកដូចជាផ្ការ ឬជាផ្លូវ ដែលពុទ្ធសាសនិកជនទាំងឡាយ តែងត្រូវការធ្វើជាញឹកញាប់ជាងទានឯទៀតៗ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទានដែលទាយកឱ្យចំពោះមុខបុគ្គលមួយៗ តាមសេចក្តីស្រឡាញ់ សេចក្តីពេញចិត្ត ដោយតាំងថា លោកនេះជាគ្រូអាចារ្យ អ្នកនេះជាកូនចៅ ឬថា អ្នកនេះត្រូវជាញាតិមិត្រជាដើម ហៅថា **បាដិបុគ្គលិកទាន** ។

*បាដិបុគ្គលិកទាននេះ មាន ១៤ យ៉ាងគឺ*

១- *ទាន* ចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ,

២- *ទាន* ចំពោះព្រះបច្ចេកពុទ្ធ,

៣- *ទាន* ចំពោះព្រះអរហន្ត ជាសាវ័ករបស់តថាគត,

៤- *ទាន* ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះនូវអរហត្តផល,

៥- *ទាន* ចំពោះអនាគាមិបុគ្គល,

៦- *ទាន* ចំពោះបុគ្គល ដែលប្រតិបត្តិ ដើម្បីបានលុះនូវអនាគាមិផល,

Websites: WatKhemaraRatanaram.org or WatKhmers.org

៧- *ទាន* ចំពោះសកទាគាមិបុគ្គល,

៨- *ទាន* ចំពោះបុគ្គល ដែលប្រតិបត្តិ ដើម្បីបានលុះនូវសកទាគាមិផល,

៩- *ទាន* ចំពោះសោតាបន្នបុគ្គល,

១០- *ទាន* ចំពោះបុគ្គល ដែលប្រតិបត្តិ ដើម្បីបានលុះនូវសោតាបត្តិផល,

១១- *ទាន* ចំពោះបុគ្គលខាងក្រៅព្រះពុទ្ធសាសនា តែមានសេចក្តីនឿយណាយចាកកាម,

១២- *ទាន* ចំពោះបុគ្គល ជាបុថុជ្ជនមានសីលបរិសុទ្ធ,

១៣- *ទាន* ចំពោះបុគ្គល ជាបុថុជ្ជនទ្រុស្តសីល,

១៤- *ទាន* ចំពោះសត្វតិរច្ឆាន ។

ទាន ដែលទាយកប្រគេនចំពោះសង្ឃ មិនបានចំពោះបុគ្គល ហៅថា សង្ឃគតាទក្ខិណាទាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# *សង្ឃគតាទក្ខិណាទាននេះមាន ៧ យ៉ាងគឺ*

១- *ទាន* ចំពោះឧភតោសង្ឃ គឺទាំងភិក្ខុសង្ឃ និងភិក្ខុនីសង្ឃមានព្រះពុទ្ធជាប្រធាន,

២- *ទាន* ចំពោះឧភតោសង្ឃ ក្នុងកាល ដែលព្រះតថាគត បរិនិព្វានហើយ,

៣- *ទាន* ចំពោះតែភិក្ខុសង្ឃ,

៤- *ទាន* ចំពោះតែភិក្ខុនីសង្ឃ,

៥- *ទាន* ចំពោះភិក្ខុ ដែលគេនិមន្តយកអំពីសំណាក់ឧភតោសង្ឃ,

៦- *ទាន* ចំពោះភិក្ខុ ដែលគេនិមន្តយកអំពីសំណាក់ភិក្ខុសង្ឃ,

៧- *ទាន* ចំពោះភិក្ខុនី ដែលគេនិមន្តយកអំពីសំណាក់ភិក្ខុនីសង្ឃ,

បណ្តាទានទាំងពីរចំណែកនេះ **សង្ឃគតាទក្ខិណាទាន** មានផលានិសង្សច្រើនជាង **បាដិបុគ្គលិកទាន** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## *សប្បុរិសទាន មាន ៥ យ៉ាងគឺ*

១- *សទ្ធាយ ទានំ ទេតិ* ឱ្យទានដោយសទ្ធាគឺ ឱ្យដោយចិត្តជឿកម្ម និងផលរបស់កម្មជាក់ប្រាកដថា អំពើគឺការឱ្យទាននេះ ជាអំពើមិនសូន្យសោះ អសារឥតការឡើយ ប្រាកដជានឹងត្រឡប់បានផលជារង្វាន់មកវិញពុំខាន,

២- *សក្កច្ចំ ទានំ ទេតិ* ឱ្យទានដោយគោរព គឺ គោរពទេយ្យវត្ថុ ដែលត្រូវលះឱ្យ និងគោរពបដិគ្គាហក អ្នកទទួល; គោរពទេយ្យវត្ថុនោះ ត្រូវសំអាតទេយ្យវត្ថុ ដោយផ្ចិតផ្ចង់ មិនធ្វើខ្ជីខ្ជាតាមតែបាន ឯគោរពបដិគ្គាហកៈនោះ ត្រូវសំដែងសេចក្តីរាប់រកបដិគ្គាហកៈ ដោយសេចក្តីស្មោះស្មើ មិនសំដែងអាការទ្រមឹងទ្រមើយ គឺត្រូវនិមន្តឬអញ្ជើញឡើងអាសនៈដ៏សមគួរជាដើម,

៣- *កាលេន ទានំ ទេតិ* ឱ្យទានតាមកាលគួរ គឺឱ្យតាមកាលតាមរដូវ ដែលគេត្រូវធ្វើ ត្រូវឱ្យ ដូចរដូវចូលវស្សា

Websites: WatKhemaraRatanaram.org or WatKhmers.org

និងចេញវស្សា, រដូវរងាឱ្យគ្រឿងស្លៀកដណ្តប់, រដូវក្តៅឱ្យទឹក ឬពេលដែលមានវត្ថុថ្មីថ្មោងមានផ្លែឈើជាដើម,

៨- *អនុគ្គហិតចិត្តោ ទានំ ទេតិ* គឺឱ្យទានដោយសេចក្តីអនុគ្រោះ គឺឱ្យដោយចិត្តអាណិតមេត្តា យ៉ាងទោរទន់ចំពោះសមណៈ ឬអ្នកក្រីក្រលំបាក ដែលរងទុកវេទនាដោយសេចក្តីស្រេកឃ្លានជាដើម ឱ្យបានសុខស្រួល ផុតអំពីសេចក្តីទុក្ខព្រួយ ហើយឥតតាំងចិត្តថា នឹងទារយកគុណបំណាច់អ្វីអំពីអ្នកទទួលទាននោះវិញឡើយ,

៩- *អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ* ឱ្យទានដោយមិនបានតាំងចិត្តបៀតបៀនខ្លួន និងអ្នកដទៃ គឺឱ្យ-ដោយតាំងចិត្តថា នឹងបំបាត់បង់នូវសេចក្តីលោភ និងសេចក្តីកំណាញ់ ហើយនឹងធ្វើឱ្យអស់អាសវក្កិលេស ដែលជាមេនាំឱ្យកើតសេចក្តីទុក្ខព្រួយក្នុងវដ្តៈប៉ុណ្ណោះ, មិនបានតាំងចិត្តឱ្យអ្នកផងគេសើ្ញចសរសើរថា ប្រសើរជាងអ្នកដទៃឡើយ, ដែលថា

Websites: WatKhemaraRatanaram.org or WatKhmers.org

មិនបៀតបៀនខ្លួន គឺមិនឱ្យអ្នកដទៃសរសើរខ្លួន, មិនបៀត-បៀនអ្នកដទៃ គឺមិនបង្អាប់បន្ទាបអ្នកដទៃ

*សប្បុរិសទាន ៥ យ៉ាងទៀតគឺ*

១- *សក្កច្ចំ ទេតិ* ឱ្យទានដោយសេចក្តីគោរព ចំពោះវត្ថុ ដែលត្រូវឱ្យ,

២- *ចិត្តីកត្វា ទេតិ* ឱ្យទានដោយតាំងសេចក្តីគោរព ចំពោះវត្ថុ និងបដិគ្គាហកៈ,

៣- *សហត្ថា ទេតិ* ឱ្យទានដោយដៃខ្លួនឯង,

៤- *អនបវិទ្ធំ ទេតិ* ឱ្យទានដោយមិនបោះឱ្យ,

៥- *អាគមនទិដ្ឋិកោ ទេតិ* ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

អធិប្បាយថា ទាយកកាលដែលធ្វើទាន បានតាំងចិត្តគោរពចំពោះតែវត្ថុប៉ុណ្ណោះ មិនធ្វើសេចក្តីអើពើចំពោះបុគ្គល

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកទទួលទាន ទោះអ្នកទទួលទាននោះ មានចរិយាដូចម្ដេចក៏ ឥតរវល់ ខំប្រឹងតែគិតសម្រិតសម្រាំងទេយ្យវត្ថុ ដែលខ្លួនត្រូវលះឱ្យនោះឱ្យស្អាតតែម្យ៉ាង យ៉ាងនេះហៅថា ឱ្យទានដោយសេចក្ដីគោរពចំពោះវត្ថុ ។

បុគ្គលកាលដែលធ្វើទាន បានតាំងចិត្តគោរព ចំពោះទេយ្យវត្ថុផង ចំពោះបុគ្គលអ្នកទទួលទានផង ទាំងពីរយ៉ាងគឺខំប្រឹងរៀបចំចាត់ចែងទេយ្យវត្ថុនោះ ឱ្យទានទាល់តែបានប្រសើរថ្លៃថ្លា មានឱជារសឆ្ងាញ់ពិសាផង ទាំងពិនិត្យមើលបុគ្គលអ្នកទទួលទានឱ្យឃើញថា មានចរិយាសណ្ដាប់ធ្នាប់ជាដើម ក៏ល្មមជាទីជ្រះថ្លា គួរកក់ក្ដៅក្នុងចិត្តផង ហើយក៏ឱ្យដោយសេចក្ដីគោរពចំពោះបុគ្គលអ្នកទទួល មិនព្រមសុខចិត្តប្រថុយឱ្យទៅខ្ជីខ្ជាឡើយ យ៉ាងនេះហៅថា ឱ្យទានដោយតាំងសេចក្ដីគោរពទាំងវត្ថុនិងបដិគ្គាហកៈ ហើយទើបឱ្យ ។

ទាយក កាលដែលធ្វើទាន បានលើកទេយ្យវត្ថុឱ្យដោយដៃខ្លួនឯង មិនប្រើអ្នកដទៃ ឱ្យគេឱ្យទេយ្យវត្ថុរបស់ខ្លួននោះជំនួស

ខ្លួនឡើយ ដោយតាំងចិត្តថា កាលអាត្មាអញ ត្រាច់រង្គាត់ក្នុងសង្សារវដ្តមិនមានទីបំផុត ដែលមិនមានដៃជើងនោះ និងប្រមាណមិនបានឡើយ បើដូច្នោះ អាត្មាអញនឹងធ្វើឱ្យបានផុតចាកវដ្តសង្សារ និងជាគ្រឿងរលាស់ខ្លួនចេញចាកភព, យ៉ាងនេះហៅថា ឱ្យទានដោយដៃខ្លួនឯង ។

ទាយក កាលដែលធ្វើទាន មិនបានបោះឱ្យឬចោលឱ្យគឺហុចឱ្យដោយសេចក្តីគួរសម សំដែងអាការទន់ភ្លន់ប្រដោយចិត្តមេត្តា, យ៉ាងនេះហៅថា ឱ្យទានដោយមិនបានបោះឱ្យ ។

ទាយក កាលដែលធ្វើទាន ដោយចិត្តជឿថាបុគ្គលអ្នកសាងទាន គង់នឹងបានផល ជាអំណោយរបស់ទាននោះមកទទួលវិញពុំខានឡើយ យ៉ាងនេះហៅថា ឱ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

## *កាលទាន ៥យ៉ាងគឺ*

១- *អាគន្តុកទានំ* ទានចំពោះ អ្នកដែលទើបនឹងមកដល់ថ្មី,

Websites: WatKhemaraRatanaram.org or WatKhmers.org

២- *គមិកទានំ* ទានចំពោះ អ្នកដែលរៀបដំណើរនឹងទៅកាន់ទីឆ្ងាយ ។

៣- *គិលានទានំ* ទានចំពោះ អ្នកជំងឺ,

៤- *ទុព្ភិក្ខទានំ* ទានក្នុងវេលា ដែលកំពុងអត់ឃ្លាន,

៥- *នវទានំ* ទានផ្លែឈើ ឬវត្ថុដែលទើបនឹងមានដំបូង ។

*អសប្បុរិសទាន ៥យ៉ាងគឺ*

១- *អសក្កច្ចំ ទេតិ* ឱ្យទានដោយសេចក្ដីមិនគោរពចំពោះវត្ថុ,

២-*អចិត្តីកត្វា ទេតិ* ឱ្យទានដោយមិនតាំងសេចក្ដីគោរព ចំពោះវត្ថុនិងបដិគ្គាហកៈ

៣- *អសហត្ថា ទេតិ* ឱ្យទានដោយការមិនឱ្យដោយដៃខ្លួនឯង,

Websites: WatKhemaraRatanaram.org or WatKhmers.org

៤- *អបវិដ្ធំ ទេតិ* ឱ្យទានដោយបោះឱ្យ,

៥- *អនាគមនទិដ្ឋិកោ ទេតិ* ឱ្យទានដោយមិនជឿថានឹងបានទទួលវិញ ។

អធិប្បាយថា បុគ្គលដែលធ្វើទានដោយបោះឱ្យឬចោលឱ្យនោះ គឺបុគ្គលអ្នកឱ្យទាន មានចិត្តជឿថា ឱ្យទានបានបុណ្យដែរ ប៉ុន្តែក្នុងពេលដែលស្មូមមកដល់ មិនមានចិត្តមេត្តានឹងចង់ឱ្យឬជ្រះថ្លានឹងឱ្យទានដល់ស្មូមនោះសោះ, ដោយសារតែទាល់ហើយក៏បោះឱ្យទៅ, ទោះស្ថិតនៅក្នុងទីជិតគ្នា ល្មមនឹងហុចឱ្យដោយស្រួលបាន ក៏បែរជាបោះឱ្យវិញ ឥតតាំងចិត្តយកបុណ្យឡើយ, ពុំនោះសោត ដោយសារតែមានទ្រព្យច្រើន ក៏បាចឬបោះឱ្យ, ដើម្បីឱ្យអ្នកក្រីក្រ ប្រជ្រែងគ្នាដណ្តើមរើសយក នឹងបានមើល ហើយសើចលេងសប្បាយប៉ុណ្ណោះ ។

បុគ្គលដែលធ្វើទានដោយមិនជឿថា នឹងបានទទួលផលវិញនោះ គឺបុគ្គលដែលមិនជឿថាមានបុណ្យ មានបាប មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

នរក មានសួគ៌ជាដើម, មនុស្សក្ដី សត្វក្ដី កើតឡើងល្អឯង អាក្រក់ឯង ឥតមានបុណ្យបាបអ្វីតាក់តែងឱ្យឡើយ, ដែលឱ្យទាននេះ ដោយតាំងចិត្តថា ព្រោះតែស្គាល់គ្នាហើយឱ្យទៅ ឬដោយសារមានមនុស្សមកសូមហើយ ក៏ឱ្យទៅប៉ុណ្ណោះ ឥតមានចិត្តនឹកកក់ក្ដៅ ឬនឹកសង្ឃឹមបន្តិចថា នឹងបានបុណ្យអំពីទានឡើយ ។

អសប្បុរិសទាននេះ មិនបានអធិប្បាយឱ្យគ្រប់ទាំង ៥ ទេ ព្រោះត្រង់បទទី ១-២-៣ នេះ មានទំនងសេចក្ដីដូចគ្នានឹងសប្បុរិសទានដែរ គ្រាន់តែផ្លាស់ពាក្យថា គោរពនិងមិនគោរពប៉ុណ្ណោះ, សូមលោកអ្នកមើលសង្កេតយកសេចក្ដីនេះផងចុះពីត្រឹម ទី ៤ - ៥ បានជាអធិប្បាយ ព្រោះមានសេចក្ដីកំបាំងខ្លះ, បើមិនអធិប្បាយ ក្រែងពីបាកសង្កេត, ទើបអធិប្បាយមកប៉ុណ្ណោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

*អសម្មតទាន ៥យ៉ាង គឺ*

១- *ឥត្ថីទានំ* ឱ្យស្រីដល់បុរស ឱ្យបុរសដល់ស្ត្រី,

២- *ឧសភទានំ* បើកលែងគោឧសភ គឺគោបាឬគោឈ្មោលដល់មេគោ ឱ្យមេគោដល់គោឧសភ,

៣- *មជ្ជទានំ* ឱ្យទានទឹកស្រវឹង,

៤- *សមជ្ជទានំ* រាំនិងច្រៀងឱ្យជាទាន ឬឱ្យទានរបាំច្រៀងរាំត្លុកក្រមាច់,

៥- *ចិត្តកម្មទានំ* ឱ្យទានរូបគំនូរស្ត្រីនិងបុរស ដែលជារូបនាំឱ្យកើតតម្រេកត្រេកត្រអាលទៅរកកាម ។

ទានទាំង ៥ នេះ លោកមិនសន្មតថា ជាទានឡើយ ព្រោះលោកមិនចាត់ថា ជាទានបានបុណ្យទេ ។ អសប្បុរិសទាន ៥ យ៉ាង និង អសម្មតទាន ទាំង ៥ យ៉ាងនេះ ពួកសាធុជនជាសប្បុរសមិនគប្បីធ្វើ ព្រោះជាទាន ឥតមានផលជាទីពឹងពំនាក់

Websites: WatKhemaraRatanaram.org or WatKhmers.org

ដល់ខ្លួនសោះឡើយ, គួរប្រឹងបំពេញតែទានឯទៀត មានសង្ឃគតាទក្ខិណាទាន ជាដើមឱ្យបរិបូណ៌ចុះ ព្រោះជាទានមានផល ជាកម្រៃជាទីពឹងដោយពិត ។

អាមិសទាន ចប់ដោយសង្ខេប ។

## ធម្មទាន

ការឱ្យធម៌ជាទានដល់អ្នកដទៃ ហៅថា **ធម្មទាន** បានដល់ការបង្រៀនធម៌ សំដែងធម៌ប្រាប់អ្នកដទៃ ដូចប្រាប់ថាធម៌នេះជាកុសល, ធម៌នេះជាអកុសល ធម៌នេះប្រកបដោយទោស, ធម៌នេះមិនប្រកបដោយទោសជាដើម ឬសំដែងប្រាប់កម្មនិងផលរបស់កម្ម ឱ្យជាក់ប្រាកដ ក្នុងលោកនេះនិងលោកខាងមុខ ឱ្យដូចជាគេចង្អុលប្រាប់ និងសំដែងធម៌ញ៉ាំងបុគ្គលដទៃ ឱ្យងាកបែរចេញអំពីអកុសលធម៌ ហើយឱ្យតំកល់នៅក្នុងកុសលធម៌វិញ, ពុំនោះ សំដែងសច្ចធម៌ ៤ ប្រការថា ធម៌នេះបុគ្គលគួរកំណត់ដឹង, ធម៌នេះគួរលះបង់, ធម៌នេះគួរធ្វើ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យជាក់ច្បាស់, ធម៌នេះគួរចំរើន ។ មួយយ៉ាងទៀត ការខំប្រឹងសរសេរ ចារចម្លងពុទ្ធវចនៈ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ឬ ចំណាយទ្រព្យ កសាងគម្ពីរដីកាច្បាប់ព្រះពុទ្ធ-សាសនាទុក សម្រាប់ឱ្យសិក្ខាកាមកុលបុត្ររៀនសូត្រ ឱ្យបានចេះដឹង បានប្រតិបត្តិកាន់តាម ដើម្បីធ្វើមគ្គផលឱ្យកើតឡើងនិងបានតវង្សព្រះពុទ្ធសាសនា ឱ្យចម្រើន តាំងនៅអស់កាលជាអង្វែងតទៅ, យ៉ាងនេះហៅថា **ធម្មទាន** ។

ធម្មទាន ចប់ដោយសង្ខេប ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ទានលក្ខណកថា

ការឱ្យទាន ជាកិច្ចដែលបុគ្គលនឹងធ្វើឱ្យបរិសុទ្ធគ្រប់គ្រាន់បានដោយកម្រជាងការកាន់សីល, ចំណែកសីលបើបុគ្គលត្រូវការកាន់ គ្រាន់តែរៀនសូត្រឱ្យចេះដឹងកិច្ច ដែលត្រូវតមត្រូវវៀរប៉ុណ្ណោះជាដើម ហើយសមាទានកាន់យកសីលនោះ អំពីសំណាក់ភិក្ខុ ឬ សាមណេរជាដើមមក ខំប្រឹងប្រព្រឹត្តសង្រួមឱ្យត្រឹមត្រូវតាមច្បាប់នោះប៉ុណ្ណោះ ក៏អាចញុំាងកុសលនោះ ឱ្យសម្រេចបរិសុទ្ធបាន ឬថា សីលនេះ បុគ្គលទាំងអ្នកមាន អ្នកក្រអាចធ្វើបានដូចគ្នា ព្រោះជាកុសល ដែលបុគ្គលត្រូវរក្សាចំពោះវីរតិចេតនាម្នាក់ ៗ បាន មិនបាច់ដាច់បង់ធនធាន ។

ឯការធ្វើទាន លុះតែបុគ្គលមានទេយ្យវត្ថុ ល្មមលះធ្វើកើតទាំងបដិគ្គាហកៈអ្នកទទួលទានក៏មានផង ទើបធ្វើបាន, វេលាដែលធ្វើនោះទៀត មានកិច្ចត្រូវខ្វល់ខ្វាយក៏ច្រើន, មិនតែប៉ុណ្ណោះឡើយ, ទានក្នុងព្រះពុទ្ធសាសនានេះ, បុគ្គលត្រូវចាត់ចែងធ្វើឱ្យត្រឹមត្រូវដោយប្រពៃ តាមពុទ្ធានុញ្ញាតផងទៀត

Websites: WatKhemaraRatanaram.org or WatKhmers.org

ទើបនឹងបានផលានិសង្សច្រើន ពេញលេញសមតាមបំណង, បើនឹងចេះតែធ្វើបំពានទាំងខ្ជីខ្ជា ដោយការមិនចេះដឹង ព្រោះអាងស័ក្តិយស ឬទ្រព្យសម្បត្តិច្រើន ធ្វើតាមទំនើងចិត្តចង់ ដោយញាណវិប្បយុត្ត មិនអាស្រ័យច្បាប់ពុទ្ធសាសនា ដែលមានមកក្នុងគម្ពីរដីកាជាគោលផងទេ, ទាននេះក៏មិនបានឈ្មោះថាធ្វើដោយប្រពៃឡើយ, ទាំងផលនៃទាននោះសោត ក៏ខ្សោយចុះមកជាលំដាប់, សមដូចព្រះពុទ្ធដីកា ដែលមានមកក្នុងទក្ខិណាវិភង្គសូត្រសំដែងអំពី *ទក្ខិណាវិសុទ្ធិ* ៤ យ៉ាងថា

១- *ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ* ទានបរិសុទ្ធអំពីអ្នកឱ្យ, មិនបរិសុទ្ធអំពីអ្នកទទួល គឺអ្នកឱ្យមានសីលបរិសុទ្ធ មានធម៌ល្អ អ្នកទទួលទ្រុស្តសីល មានធម៌អាក្រក់,

២- *បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ* ទានបរិសុទ្ធអំពីអ្នកទទួល, មិនបរិសុទ្ធអំពីអ្នកឱ្យ គឺ

អ្នកឱ្យជាអ្នកទ្រុស្រ្តសីល មានធម៌អាក្រក់ អ្នកទទួលមានសីលបរិសុទ្ធ មានធម៌ល្អ,

*៣- នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ* ទានមិនបរិសុទ្ធអំពីអ្នកឱ្យផង អំពីអ្នកទទួលផង គឺអ្នកឱ្យ ជាអ្នកទ្រុស្រ្តសីល មានធម៌អាក្រក់, អ្នកទទួល ក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា,

*៤- ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គហកតោ ច-* ទានបរិសុទ្ធអំពីអ្នកឱ្យផង បរិសុអំពីអ្នកទទួលផង គឺអ្នកឱ្យ ក៏មានសីលបរិសុទ្ធ មានធម៌ល្អ, អ្នកទទួល ក៏មានសីលបរិសុទ្ធ មានធម៌ល្អ ដូចគ្នាទាំងពីរខាង ។

ព្រោះហេតុនោះ ទើបមានអត្ថាធិប្បាយថា **ទាន** នេះជាកិច្ចកម្របុគ្គលធ្វើបានដោយប្រពៃ ។ ការធ្វើទាននេះ លុះតែ

Websites: WatKhemaraRatanaram.org or WatKhmers.org

ធ្វើឱ្យប្រកបដោយអង្គ ៦ ទើបមានផលានិសង្សច្រើន, ឯអង្គ ៦ ប្រការនោះគឺ អង្គខាងអ្នកឱ្យ ៣ ,អង្គខាងអ្នកទទួល ៣ ។

*អង្គអ្នកឱ្យ ៣ យ៉ាងគឺ*

*១- បុព្វេវ ទានា សុមនោ ហោតិ* អ្នកឱ្យមានចិត្តសោមនស្សត្រេកអរក្នុងកាលមុនឱ្យ,

*២- ទទំ ចិត្តំ បសាទេតិ* អ្នកឱ្យញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងពេលកំពុងឱ្យ,

*៣- ទត្វា អត្តមនោ ហោតិ* អ្នកឱ្យមានចិត្តត្រេកអរត្រួតថែមតាមទានដែលឱ្យរួចហើយ ។

**អង្គ** ទាំង ៣ យ៉ាងនេះ ហៅថា **បុព្វចេតនា ១ មុញ្ចនចេតនា ១** និង **អបរាបរចេតនា ១** ដូច្នេះវិញក៏បាន ។

*អង្គអ្នកទទួល ៣យ៉ាងគឺ*

*១- វីតរាគា វា ហោន្តិ រាគវិនយាយ វា*

*បដិបន្នា* បដិគ្គាហកៈអ្នកទទួលទាន អស់រាគៈ (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់រាគៈ ,

២- *វីតទោសោ វា ហោន្តិ ទោសាវិនយាយ វា បដិបន្នា* បដិគ្គាហកៈអ្នកទទួលទាន អស់ទោសៈ (ពី-ខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់ទោសៈ,

៣- *វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា* បដិគ្គាហកៈ អ្នកទទួលទាន អស់មោហៈ (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់មោហៈ ។

រួម **អង្គ** ទាំងពីរចំណែកត្រូវជា ៦ ប្រការ ហៅថា **ឆឡង្គ-ទានៈ** ប្រែថា ទានប្រកបដោយអង្គ ៦ ។ ទានប្រកបដោយអង្គ ៦ ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថា នឹងបានអានិសង្សច្រើន, បុគ្គលមិនអាចនឹងគណនារាប់ថា មានចំនួនប៉ុណ្ណេះប៉ុណ្ណោះ បានឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

មួយទៀត ដែលហៅថា ទានដ៏ប្រពៃនោះ មានស្ថាន ៧ ប្រការគឺ

១- *តណ្ហុត្តរិយទានំ* ទានដើម្បីឆ្លងចាកតណ្ហា ដែលជាគ្រឿងនាំ ឬបណ្ដើរសត្វឱ្យអន្ទោលកើតស្លាប់ក្នុងភពតូចភពធំ,

២- *ចិត្តីការទានំ* ទានដោយសេចក្ដីគោរព គឺ គោរពគ្រប់ទ្វារទាំងបី ព្រមទាំងទេយ្យវត្ថុ ដែលត្រូវលះឱ្យ មិនឱ្យដោយអាការសោះអង្គើយ,

៣- *ហិរោត្តប្បទានំ* ទានដោយសេចក្ដីខ្មាស់បាប ក្ដៅនឹងបាប,

៤- *និរវសេសទានំ* ទានដោយមិនគិតសំចៃទុក មិននឹកស្ដាយក្រោយ,

៥- *ទក្ខិណេយ្យទានំ* ទានចំពោះទក្ខិនេយ្យ-បុគ្គល,

Websites: WatKhemaraRatanaram.org or WatKhmers.org

៦- *សោមនស្សបរិវារទាន* ទានដោយសោមនស្សរីករាយ និងការពិចារណា ឃើញប្រយោជន៍ជាក់លាក់ មិនស្រវិនសាវាន់ ដោយវិចិកិច្ឆានីវរណៈ,

៧- *អលង្ការ បរិវារ ទាន* ទានជាគ្រឿងអលង្ការ និងជាបរិវារនៃចិត្ត គឺតាំងចិត្តថានឹងយកការឱ្យទានមកជាគ្រឿងប្រដាប់សម្រាប់អប់រំជាលំអរបស់ចិត្ត ជាគ្នានឹងចិត្ត ។

ចំណែកបច្ច័យ ៤ យ៉ាង (តាមដំណើរសេចក្ដីក្នុងវិន័យ) បើទាយកធ្វើទានដោយបច្ច័យណាមួយ ចំពោះសមណៈសា-សនា ទោះជា **បាដិបុគ្គលិកទាន** ក្ដី ជា **សង្ឃទាន** ក្ដី លុះតែធ្វើឱ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាត ល្មមគួរដល់សមណៈ ក្នុងសាសនាទទួលប្រើប្រាស់បាន មិនទាស់នឹងវិនយកិច្ច ទើបទាននោះមានផលច្រើន ។ បច្ច័យ ៤ យ៉ាង ដែលនឹងធ្វើឱ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាតនោះ ដូចសេចក្ដីតទៅនេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

# **ចីវរប្បច្ច័យ**

សំពត់សម្រាប់បព្វជិតស្លៀកដណ្តប់ ហៅថា **ចីវរប្បច្ច័យ** ។ សង្ឃាដី, ចីពរ, ស្បង់, សំពត់ចីវរទាំង៣នេះមានពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គ ត្រង់ចីវរក្ខន្ធកៈ ដែលអនុញ្ញាតឱ្យធ្វើចីវរប្រកបដោយខណ្ឌ មានបញ្ចខណ្ឌជាដើម គឺឱ្យប្រកបដោយឈ្មោះ ៤ យ៉ាង, អង្គ ៩ យ៉ាង, ត្រូវកាត់ឱ្យដាច់ចេញរួចសឹមដេរភ្ជាប់គ្នា, ធ្វើឱ្យត្រូវខ្នាត គឺកុំឱ្យធំពេកតូចពេក ។

*ឈ្មោះចីវរ ៤ យ៉ាងគឺ*

*បញ្ចខណ្ឌ ១ សត្តខណ្ឌ១ នវខណ្ឌ ១ ឯកាទសខណ្ឌ ១* ។ សង្ឃដី ចីពរ ស្បង់ ដែលធ្វើដោយសំពត់ ៥ ផ្ទាំង, ក្នុងផ្ទាំងមួយៗ មានកន្លែងពីរៗ គឺកន្លែងធំ១តូច១ ត្រូវជា ១០ កន្លែង ហៅថា **ចីវរបញ្ចខណ្ឌ** ។ ដែលធ្វើដោយសំពត់៧ផ្ទាំង មានកន្លែង១៤ហៅថា **ចីវរសត្តខណ្ឌ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ដែលធ្វើដោយសំពត់ ៩ ផ្ទាំង មានកន្លែង ១៨ ហៅថា **ចីវរនវខណ្ឌ** ។ ដែលធ្វើដោយសំពត់ ១១ ផ្ទាំង មានកន្លែង ២២ ហៅថា **ចីវរឯកាទសខណ្ឌ** ។ ដេរចីវរក្នុងផ្ទាំងមួយៗ ឱ្យមានកន្លែង ២ ដូច្នេះ ទើបត្រូវតាមបែបក្នុងវិន័យ ។

*អង្គចីវរ ៩ យ៉ាងគឺ*

១- *កុសិ* អនុវាតជុំវិញ និង ខ្នងវែងៗ,

២- *អឌ្ឍកុសិ* ខ្នង់ខ្លីៗ ត្រង់ចន្លោះៗ,

៣- *មណ្ឌល* កន្លែងធំវែងៗ ក្នុងខណ្ឌមួយៗ,

៤- *អឌ្ឍមណ្ឌល* កន្លែងតូចខ្លីៗ ក្នុងខណ្ឌមួយៗ,

៥- *វិវដ្ដៈ* ខណ្ឌកណ្ដាល,

---

១ ក្នុងផ្ទាំងមួយៗ ត្រូវបែងសម្រុងជា ៣ ភាគ, យកពីរភាគ ធ្វើជាមណ្ឌលៈ (កន្លែងធំ) គឺបែងប្រវែងឱ្យវែងជាងអឌ្ឍមណ្ឌលៈ (ពីរភាគជាមួយភាគ) បែងយកមួយភាគធ្វើអឌ្ឍមណ្ឌលៈ (កន្លះភាគពីរកន្លែងធំ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៦- *អនុវិវដ្ដ* ខណ្ឌទាំងពីរខាងអមបន្ទាប់ខណ្ឌកណ្ដាល[១]

៧- *គីវេយ្យកៈ* សំពត់ដែលប៉ះឱ្យមាំត្រង់កន្លែងរុំបិទបាំងក ឬកន្សែងដែលឃ្លុំនៅត្រង់ក,

៨- *ជង្ឃេយ្យកៈ* សំពត់ដែលប៉ះឱ្យមាំត្រង់កន្លែងស្មង ឬកន្សែងដែលឃ្លុំនៅត្រង់ស្មង់,

៩- *ពាហន្តៈ* ខណ្ឌបំផុតទាំងពីរខាងត្រង់កន្សែងដែលឃ្លុំនៅដើមដៃខាងឆ្វេង ។

ចីវរដែលថា ត្រូវកាត់ឱ្យដាច់ជាកំណាត់ៗ ហើយដេរភ្ជាប់គ្នា ទើបសមគួរដល់ភេទសមណនោះ មានពុទ្ធានុញ្ញាតថា *អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដឹ ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកំ* (ប្រែថា) "ម្នាលភិក្ខុទាំងឡាយ

---

១ បើចីវរសត្តខណ្ឌ មានអនុវិវដ្ដៈ ៤ គឺម្ខាងមានពីរៈ ចីវរនវខណ្ឌ មានអនុវិវដ្ដៈ ៦ តែម្ខាងមានបីៈ ចីវរឯកាទសខណ្ឌ មានអនុវិវដ្ដៈ ៨ គឺម្ខាងមានបួន

Websites: WatKhemaraRatanaram.org or WatKhmers.org

តថាគតអនុញ្ញាត (ឱ្យអ្នកទាំងឡាយប្រើ) សង្ឃាដីដែលកាត់ដាច់, ចីពរដែលកាត់ដាច់, ស្បង់ដែលកាត់ដាច់, ។ បុន្តែមានពុទ្ធានុញ្ញាតបន្ទូរមកទៀតថា បើសំពត់នោះខ្វះ លៃកាត់ឱ្យដាច់ទាំង ៣ ធ្វើមិនទាន់ទេ, នឹងកាត់ពីរមិនកាត់មួយក៏បាន, បើកាត់ត្រឹមពីរហើយនៅតែខ្វះ ធ្វើមិនគ្រាន់ទៀត, នឹងកាត់តែមួយមិនកាត់ពីរក៏បាន, (មានពុទ្ធប្បញ្ញត្តិ មិនឱ្យខានកាត់ទាំង ៣), បើភិក្ខុប្រើប្រាស់ចីវរមិនកាត់ទាំង. ៣ ត្រូវអាបត្តិទុក្កដ ។

ឯថ្នេរដែលដេរភ្ជាប់គ្នា គ្រប់ខណ្ឌគ្រប់កន្សែងជាខ្នង់នោះត្រូវដេរជាថ្នេរតូចៗ កុំឱ្យពាក់ប្រក់តម្រួតលើគ្នាជាពីរជាន់ គឺត្រង់ផ្ទៃក្នុងខ្នង់តូចៗនោះ ត្រូវធ្វើតែមួយជាន់ស្មើគ្នាទាំងអស់ លើកតែអនុវាតជុំវិញចេញ, ដ្បិតមានពុទ្ធានុញ្ញាតថា *ឯកច្ចិយំ* ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ “ចីពរដេរមួយជាន់, ស្បង់ដេមួយជាន់” ដូចគ្នា; ចំណែកខណ្ឌនិងកន្សែងរបស់ស្បង់ក៏ដូចគ្នានឹងចីពរដែរ ។ ក្នុងយោជនាដីកាវិន័យ មានសេចក្តីពន្យល់អំពីការដេរថ្នេរចីពរ និង ស្បង់នោះដោយសេចក្តី

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាក់ច្បាស់ថា *អាទិសន្ទេន ទ្វិន្នំ ខណ្ឌានំ អន្តរា មាតិកាសណ្ឋានេន ឋបិតបជញ្ជ ទីឃបជញ្ជ ទដ្ឋព្វំ* ។ (ប្រែថា) តាមអាទិសព្ទ គឺសព្ទដែលប្រែថា “ជាដើម” បណ្ឌិតគប្បីជ្រាបថា សំពត់ដែលគេដេរ ដោយសណ្ឋានដូចជាសណ្ឋានរបស់ប្រឡាយទឹក ត្រង់ចន្លោះនៃខណ្ឌទាំងពីរ គឺខ្វង់វែង ៗ (ទាំងប៉ុន្មាន) ក្តី សំពត់អនុវាតវែងៗ (ទាំងប៉ុន្មាន)ក្តី (ហៅថាកុសិ) ។ សង្ឃាដីត្រូវធ្វើពីរជាន់, ចីពរមួយជាន់, ស្បង់មួយជាន់ បើសង្ឃាដីបួនជាន់, ចីពរត្រូវធ្វើពីរជាន់, ស្បង់ពីរជាន់,ដោយពុទ្ធានុញ្ញាតថា *អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទ្វិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ ឧតុទ្ធតានំ ទុស្សានំ ចតុគុណំ សង្ឃាដឹ ទ្វិគុណំ ឧត្តរាសង្គំ ទ្វិគុណំ អន្តរវាសកំ បំសុកូលេ យាវទត្ថំ បាបណិកេ ឧស្សាហោ ករណីយោ អនុជានាមិ ភិក្ខវេ អគ្គឡំ តុន្នំ ឱវដ្ដិកំ កណ្ឌូសកំ ទឡ្ហីកម្មំ* (ប្រែថា) ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មី ឬសំពត់ ដែលគេទើបនឹងគក់ម្តង ថាគត

Websites: WatKhemaraRatanaram.org or WatKhmers.org

អនុញ្ញាតឱ្យអ្នកទាំងឡាយ ធ្វើសង្ឃាដីពីរជាន់ ចីពរមួយជាន់ ស្បង់មួយជាន់, បើសំពត់នោះចាស់ តថាគតអនុញ្ញាតឱ្យធ្វើសង្ឃាដីមួយជាន់ ចីពរពីរជាន់ ស្បង់ពីរជាន់ អ្នកទាំងឡាយគួរស្វែងរកសំពត់បង្សុកូល សំពត់ដែលធ្លាក់ចុះចាករានផ្សារតាមត្រូវការចុះ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យអ្នកទាំងឡាយប៉ះផុល ដាក់ក្រវិលកណ្ដុំ និងដាក់កណ្ដុំ ធ្វើឱ្យមាំមួន" ។ ខ្នាតចីវរដែលថា ធ្វើឱ្យត្រូវនឹងប្រមាណកុំឱ្យធំពេកតូចពេកនោះ គឺធ្វើកុំឱ្យប៉ុនចីវរព្រះសុគត ។ ខ្នាតចីពរសង្ឃាដីព្រះសុគត បណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត, បើគឹតជាហត្ថជាងឈើបណ្ដោយ ១៣ ហត្ថ ១ ចំអាម ទទឹង ៩ ហត្ថ ។ សេចក្ដីនេះ ពោលតាមពាក្យព្រះអដ្ឋកថាចារ្យ ដែលសម្ដែងទុកក្នុងគម្ពីរទុតិយសមន្តប្បាសាទិការអដ្ឋកថា ថា *តស្ស បមាណំ ឧកដ្ឋបរិច្ឆេទេន សុគតចីវរតោ ឩនកំ វដ្ដតិ ។ លាមកបរិច្ឆេទេន សង្ឃាដិយា ច ឧត្តរាសង្គស្ស ច ទីឃតោ មុដ្ឋិបញ្ចកំ តិរិយតោ*

Websites: WatKhemaraRatanaram.org or WatKhmers.org

*មុដ្ឋិត្តិកំ បមាណំ វដ្ដតិ ។ អន្តរវាសកោ ទីឃតោ មុដ្ឋិបញ្ចកោ តិរិយំ ទ្វិហត្ថោបិ វដ្ដតិ ។ វុត្តប្បមាណតោ បន អតិរេកញ្ច ឩនកញ្ច បរិក្ខារចោឡន្តិ អធិដ្ឋាតព្វំ,* សេចក្ដីថា ចីវរត្រូវធ្វើឱ្យតូចជាងចីវរព្រះសុគត ទើបប្រើប្រាស់បាន ។ ខ្នាតចីពរសង្ឃាដីយ៉ាងតូចបំផុត ត្រូវធ្វើបណ្ដោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ១ គក់, ខ្នាតស្បង់បណ្ដោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ។ បើត្រៃចីវរដែលមានខ្នាតធំ ឬ តូចជាងខ្នាតដែលនិយាយមកនេះ អធិដ្ឋានមិនឡើងជាចីពរ ស្បង់ សង្ឃាដីឡើយ, ត្រូវអធិដ្ឋានចេញឈ្មោះជាបរិក្ខាចោឡៈ ទើបប្រើប្រាស់បាន ។

អំពីទំហំអនុវាតនិងខ្នង់ចីវរទាំងនេះ មិនឃើញមានបញ្ញត្តិឱ្យធ្វើទំហំប៉ុន្មានៗ ជាដាច់ខាតទេ, ប៉ុន្តែមានសេចក្ដីក្នុងអដ្ឋកថា ចីវរក្ខន្ធកៈ ប្រាប់អំពីវិធីចែកសំពត់ថា បើសំពត់តិច ភិក្ខុចែកគ្នាមិនគ្រាន់ ត្រូវឱ្យកាត់ច្រៀកជាចម្រៀកៗ យ៉ាងតូចបំផុតខាងទទឹង ៤ ធ្នាប់ ខាងបណ្ដោយលៃឱ្យល្មមធ្វើអនុវាតបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីនេះ សឱ្យឃើញថា អនុវាតចីវរ យ៉ាងតូចបំផុតទំហំត្រឹម ៤ ធ្នាប់ក៏ប្រើបាន ។ ឧត្តរាសង្គៈ និង សង្ឃាដី បើធ្វើអនុវាតទំហំ ១៥ សង់ទីម៉ែត្រ ខ្ពង់ទំហំ ៥ សង់ទីម៉ែត្រ, ស្បង់ធ្វើអនុ-វាតទំហំ ៨ ឬ ៩ សង់ទីម៉ែត្រ ខ្ពង់ទំហំ ៤ ឬ ៥ សង់ទីម៉ែត្រកន្លះ នេះល្មម មិនធំពេកមិនតូចពេក ។ ដំណើរនេះ អ្នកស្ទាត់ក្នុងការលៃលក គួរលៃកាត់ឱ្យល្មមសមរម្យចុះ ។

## បិណ្ឌបាតបច្ច័យ

ភោជនាហារ ដែលត្រូវឆាន់បានតែក្នុងពេល គឺតាំងពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ហៅថា **បិណ្ឌបាតបច្ច័យ** ។ វត្ថុដែលជាភោជនាហារនោះ មានច្រើនយ៉ាងគឺ បាយ, នំ ត្រី, សាច់ ផ្លែឈើជាដើម ។ វត្ថុណា ដែលលោករាប់បញ្ចូលថាជាភោជនាហារហើយ ទាយក មិនគប្បីប្រគេនដល់ភិក្ខុក្នុងវេលាវិកាល គឺតាំងពីវេលារសៀលទៅដល់យប់ឱ្យលោកទទួលផ្ទាល់ដៃឡើយ, បើប្រគេនដោយសំដីជាកប្បិយរៅ-

Websites: WatKhemaraRatanaram.org or WatKhmers.org

ហារបាន គឺបវារណាឱ្យតែលោកដឹង ហើយប្រគល់វត្ថុនោះឱ្យដល់កប្បិយការកៈ គឺកូនសិស្សរបស់លោកឱ្យទទួលរៀបចំទុកដាក់សម្រេចកិច្ចប្រគេនលោក, ចំណែកលោកគ្រូគ្រាន់តែទទួលដឹងដោយចិត្តប៉ុណ្ណោះក៏បានហើយ, បើប្រគេនដូច្នេះ ទើបលោកឆាន់ភោជននោះ ទៅថ្ងៃក្រោយទៀតបានឥតមានទោស ។ ភោ-ជននេះ កុំថាឡើយតែភិក្ខុទទួលផ្ទាល់ដៃក្នុងកាលខុស សូម្បីតែទទួលភោជនណាមួយក្នុងកាលត្រូវ ហើយទុកដាក់ដោយខ្លួនឯងឱ្យកន្លងរាត្រី ១ ឡើងទៅ, ភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិបាចិត្តិយៈ ត្រង់សន្និធិការកសិក្ខាបទដោយពិត ។ មួយទៀតភោជនាហារ ដែលត្រូវលេបចូលទៅក្នុងបំពង់កទាំងប៉ុន្មាន លុះតែគេប្រគេនដោយត្រឹមត្រូវ ទើបភិក្ខុឆាន់បាន វៀរលែងតែទឹកសុទ្ធ គឺទឹកដែលឥតលាយដោយវត្ថុអ្វីមួយ និងឈើស្ទន់ចេញមិនបាច់ប្រគេនទេ គ្រាន់តែយកទៅដាក់ក្បែរ ភិក្ខុប្រើប្រាស់ឆាន់បាន, ឯការប្រគេននោះ ត្រូវឱ្យប្រកបដោយអង្គ ៥ យ៉ាងទើបហៅថា ប្រគេន, ភិក្ខុទទួលឆាន់បានឥតមានទោស ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## អង្គ ៥ យ៉ាងនោះគឺ

១- *ថាមមជ្ឈិមស្ស បុរិសស្ស សច្ចារណៈ-មត្តំ ហោតិ* វត្ថុដែលមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្តាលលើកម្នាក់ឯងរួច តែមិនគប្បីសែងវត្ថុនោះ ប្រគេនជាមួយគ្នាទាំងពីរនាក់ឡើយ, ។

២- *ហត្ថបាសោ បញ្ញាយតិ* ហត្ថបាសប្រកដ គឺអ្នកប្រគេនឋិតនៅក្នុងហត្ថបាស ២ ហត្ថ ១ ចំអាម ។ **ហត្ថ-បាសៈ** ប្រែថា, អន្ទាក់ដៃ, ក្នុងទីនេះ ជាឈ្មោះឱកាសដែលត្រូវលាតដៃប្រគេន លាតដៃទទួល មិនលាតលូកឬឈោងដៃចូលឱ្យកើនលើសប្រមាណ ។ ឯពិធីដែលនឹងលៃហត្ថបាស ២ ហត្ថ ១ ចំអាមនោះ ដូច្នេះគឺ ចំណែកខាងទាយក (អ្នកប្រគេន) ត្រូវគឹតហត្ថបាស ពីត្រឹមទីបំផុតខាងក្នុងអវយវៈចូលទៅ, ចំណែកខាងបដិគ្គាហកៈ គឺភិក្ខុអ្នកទទួល ត្រូវគឹតពីត្រឹម

---

ត្រង់នេះចូរមើល ក្នុងសមន្តប្បាសាទិកា វិនយដ្ឋកថា និងកង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ ទើបឃើញសេចក្តីទូលំទូលាយជាងនេះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទីបំផុតខាងក្រៅអវយវៈចូលមក, ផ្សំគ្នាទៅ ឱ្យបានប្រវែង២ហត្ថ ១ ចំអាម, គឺបើទាយកឈរប្រគេនចំពីមុខ (ភិក្ខុ ក៏ឈរទទួលដែរ ដូចយ៉ាងទទួលភត្ត ដែលគេដាក់បាត្រ) ត្រូវគឹតពីត្រឹមមេជើង ទាយកចូលទៅទល់នឹងចុងបំផុតកែងជើងភិក្ខុ ឱ្យបានប្រវែង ២ ហត្ថ ១ ចំអាម, យ៉ាងនេះ ហៅថា ហត្ថបាស (មួយអន្ទាក់ដៃ) គឺល្មមលាតដៃប្រគេន លាតដៃទទួលបានដោយគោរព, បុរសក្តី ស្ត្រីក្តី អាចប្រគេន ឬដាក់បាត្របានដូចគ្នា ។ ទាយកនិងបដិគ្គាហកៈ អង្គុយដូចគ្នាក្តី ម្នាក់ឈរ ម្នាក់អង្គុយ ឬដេកក្តី ប្រគេនចំពីមុខក្តី ពីក្រោយឬពីខាងក្តី ក៏មានទំនងដូចន័យនេះដែរ, អ្នកប្រគេន ត្រូវគឹតពីខាងក្នុងចូលទៅ អ្នកទទួល ត្រូវគឹតពីខាងក្រៅចូលមក រួមប្រវែងហត្ថបាសទៅឱ្យបាន ២ ហត្ថ ១ ចំអាម, មិនមែនចាំបាច់វាស់ទេ គ្រាន់តែលៃស្មានមើលឱ្យឃើញល្មមបាន ២ ហត្ថ ១ ចំអាម ប៉ុណ្ណោះ ឬឱ្យជិតជាងនេះបន្តិច ក៏ឥតទាស់, កុំឱ្យតែជិតពេក បើស្ត្រីក្រែងប្រគេន ឬដាក់បាត្រពុំបាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

៣- *អភិហារោ បញ្ញាយតិ* អ្នកប្រគេនបន្ទន់ខ្លួន បង្អោនវត្ថុចូលមក គឺបង្អោនចូលមកសំដែងឱ្យឃើញថា ជាអ្នកត្រូវការប្រគេនដោយគោរពពិតមែន ។

៤- *ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា ទេតិ* ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តី ប្រគេន គឺពិតជាមានគេប្រគេនមែន ។

៥- *តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ* ភិក្ខុទទួលវត្ថុនោះ ដោយកាយក្តី ដោយវត្ថុដែលជាប់ដោយកាយក្តី ។

ពាក្យថា ទទួលដោយកាយនោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុលូកដៃទៅទទួលចាប់កាន់វត្ថុ ដែលគេប្រគេននោះដោយផ្ទាល់នឹងដៃ មិនមានយកភាជន៍ អ្វីនីមួយមានជើងពានជាដើម ទៅទទួលយក ហៅថា ទទួលដោយកាយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ពាក្យថា **ទទួលដោយវត្ថុដែលជាប់ដោយកាយ** នោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុកាន់សំពត់ ឬភាជន៍មានជើងពានជាដើម លូកទៅទទួលទស់យក ឬផ្ទេរយកវត្ថុដែលគេប្រគេននោះ មិនបានទទួលទស់យកផ្ទាល់នឹងដៃសុទ្ធ ហៅថា **ទទួលដោយវត្ថុដែលជាប់ដោយកាយ** ។

ន័យមួយទៀត ទេយ្យវត្ថុជា **ពីជគាម** ឬ **ភូតគាម** គឺវត្ថុដែលមានគ្រាប់, មើម ឫស, ទង ជាពូជល្មមដុះទៅទៀតបាន ដូចផ្លែម្នេសទុំ, ត្របែកទុំ, មើមដម្លូង, ដើមអំពៅ, សណ្ដែកបណ្ដុះ, ទងដម្លូង, ទងកញ្ឆែតជាដើម, បើទាយកមានប្រាថ្នានឹងធ្វើទានដល់សមណៈ ក្នុងសាសនា គប្បីអុជ, ដុត ពុះ, ចោះ, ចុច ឬ ស្រុស ធ្វើឱ្យសម្រេចជារបស់កប្បិយៈ ត្រូវតាមពុទ្ធានុញ្ញាត ដែលព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតសមណៈកប្ប ៤ ប្រការ ដល់ភិក្ខុទាំងឡាយ នោះទើបលោកទទួលឆាន់បាន មិនខុសនឹងបញ្ញត្តិក្នុង **ភូតគាមសិក្ខាបទ** ។

## *សមណកប្ប ៥ ប្រការនោះគឺ*

១- *អគ្គិបរិចិតំ* វត្ថុដែលគេអុជដុតកំដៅភ្លើងឬស្រុស,

២- *សត្ថបរិចិតំ* វត្ថុដែលគេពុះចោះចិតដោយសស្ត្រា

៣- *នខបរិចិតំ* វត្ថុដែលគេចុច ឬកេះដោយក្រចក,

៤- *អពីជំ* វត្ថុដែលគ្មានពូជដុះទៅទៀតបាន (ផ្លែខ្ចី),

៥- *និព្វដពីជំ* ផ្លែដែលមានពូជតែបន្លេចយកគ្រាប់ចេញបាន ។

ការទទួលប្រគេនប្រកបដោយអង្គ ៥ និង អង្គនៃសមណ-កប្ប ៥ ប្រការនេះ គួរសាធុជនជាសប្បុរសទាំងឡាយ ខំយកចិត្តទុកដាក់សង្កេតមើលឱ្យចេះ ចូលចិត្តចាំស្ទាត់កុំខាន ព្រោះជាកិច្ច ឬជាផ្លូវ ដែលអស់លោកទាំងឡាយតែងធ្វើរឿយៗ ។

## **សេនាសនប្បច្ច័យ**

ទីសម្រាប់ដេក អង្គុយ មានកុដិសាលាជាដើម ហៅថា

Websites: WatKhemaraRatanaram.org or WatKhmers.org

**សេនាសនប្បច្ច័យ** ។ **សេនាសនប្បច្ច័យ** នេះ មានច្រើនប្រការណាស់ នឹងនាំយកតែបច្ច័យណា ដែលមានដំណើរទាក់ទងច្រើន ដោយវិនយកិច្ច ហើយទាំងជនអ្នកមានសទ្ធាក៏តែងកសាងរឿយៗ មកអធិប្បាយ ។

ទីសេនាសនៈ គឺ កុដិ សាលា វិហារ បើទាយកនឹងគិតសាងត្រង់ទីណាមួយចំពោះភិក្ខុសង្ឃ លុះតែឱ្យសង្ឃសំដែងទីឱ្យជាមុន គឺឱ្យសង្ឃពិនិត្យទីកន្លែងដែលបម្រុងនឹងកសាងនោះឱ្យឃើញថាជាទីបរិសុទ្ធ ផុតចាកសេចក្ដីរង្កៀស ឥតមានទាក់ទាមទៅលើទីដីអ្នកណាមួយទេ ទាំងសង្ឃអនុញ្ញាត យល់ព្រមឱ្យធ្វើ ទើបទាយកនោះអាចធ្វើបាន ទាំងភិក្ខុសង្ឃក៏ទទួលយកនៅអាស្រ័យបាន ។

ចំណែកគ្រែនិងតាំង ដែលត្រូវធ្វើឱ្យមានជើងនោះ យ៉ាងខ្ពស់ផុតត្រឹម ៨ ធ្នាប់ព្រះសុគត គិតពីត្រឹមមេគ្រែខាងក្រោមចុះមក គឺកំពស់ ២៤ ធ្នាប់ ជាងឈើ ត្រូវជា ៤០ សងទីម៉ែត្រ ដែលនិយមប្រើសព្វថ្ងៃនេះ ហើយកុំញាត់ដោយគបូសំឡី ទើបភិក្ខុទទួលប្រើប្រាស់បាន មិនកន្លងបញ្ញត្តិត្រង់ឆេទនកសិក្ខាបទ

Websites: WatKhemaraRatanaram.org or WatKhmers.org

និង តុលោនទ្ធសិក្ខាបទ ។ គ្រឿងកម្រាល មិនត្រូវធ្វើញាត់ដោយគបឬសំឡីឡើយ គប្បីញាត់ដោយវត្ថុណាមួយ ដ៏សមគួរតាមពុទ្ធានុញ្ញាត ដែលទ្រង់អនុញ្ញាតពូក ៥ យ៉ាង ឱ្យភិក្ខុប្រើប្រាសនោះ ទើបភិក្ខុទទួលប្រើប្រាស់បាន ឥតមានទោស ។

*ពូក ៥ យ៉ាងនោះគឺ*

១-*ឧណ្ណាភិសិ* ពូកញាត់រោមកែះ,

២- *ចោឡភិសិ* ពូកញាត់កំណាត់សំពត់,

៣- *វាកភិសិ* ពូកញាត់សំបកឈើ,

៤- *តិណភិសិ* ពូកញាត់ស្មៅ,

៥- *បណ្ណភិសិ* ពូកញាត់ស្លឹកឈើ,។

## គិលានភេសជ្ជប្បច្ច័យ

ថ្នាំជាបច្ច័យសម្រាប់រក្សាជំងឺ ហៅថា **គិលានភេសជ្ជប្បច្ច័យ** ។ ថ្នាំត្រាំដោយទឹកមូត្រគោនិងភេសជ្ជៈ ៥យ៉ាង គឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ជាដើម, ភេសជ្ជៈ ទាំងប៉ុន្មាននេះ លុះតែប្រគេនត្រឹមត្រូវតាមអង្គនៃការប្រគេន ដូចបិណ្ឌបាតប្បច្ច័យដែរ ទើបភិក្ខុ ទទួលឆាន់បាន ឥតមានទោស ។

បណ្ដាបច្ច័យទាំង ៤ យ៉ាង ដូចពណ៌នាមកហើយ ខាងលើនោះ ចីវរប្បច្ច័យ និង សេនាសនប្បច្ច័យ ទាយកប្រគេនដោយវាចា គឺគ្រាន់តែសូត្របាលីវេរ ឬគេនិយាយប្រគេនជាសម្រាយក៏បានឈ្មោះថា ប្រគេនពិត, ភិក្ខុទទួលប្រើប្រាស់បាន ឥតមានទោស ព្រោះជាបច្ច័យមិនបានលេបចូលទៅក្នុងបំពង់ក ។

ឯបិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ទោះទាយកបាននាំយកមកតំកល់ទុក ក្នុងទីចំពោះមុខភិក្ខុសង្ឃ ជាប់ហត្ថបាស រួចសូត្រវេរជាបាលី ឬសម្រាយ សព្វគ្រប់ហើយក៏ត្រូវតែទាយកលើកបច្ច័យនោះប្រគេន ឱ្យត្រូវតាមអង្គទាំង ៥ ប្រការនោះទៀត ទើបហៅថា ប្រគេន, ភិក្ខុក៏ទទួលឆាន់បាន ឥតមានទោស ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ន័យមួយទៀត បិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ទាំងពីរនេះ ចែកទៅតាមកាលមាន ៤ យ៉ាង គឺ

១- *យាវកាលិក* បច្ច័យដែលភិក្ខុគួរឆាន់បានពីត្រឹមពេលព្រឹកទៅទល់នឹងថ្ងៃត្រង់,

២- *យាមកាលិក* បច្ច័យដែលភិក្ខុគួរទទួលទុកដាក់ឆាន់បានពីត្រឹមពេលព្រឹកទៅទល់អរុណរះ (១ យប់ ១ ថ្ងៃ),

៣- *សត្តាហកាលិក* បច្ច័យដែលភិក្ខុទទួលទុកដាក់ឆាន់បាន យ៉ាងយូរត្រឹម ៧ ថ្ងៃ,

៤- *យាវជីវិក* បច្ច័យដែលភិក្ខុទទួលទុកដាក់ឆាន់បានដរាបទល់នឹងអស់ (មិនមានកំណត់ថ្ងៃ) ។

## អធិប្បាយ

១- វត្ថុដែលរាប់ថា ជាភោជនាហារទាំងប៉ុន្មាន មានបាយ, នំ ត្រី, សាច់ និង ដើមឈើ ផ្លែឈើ មានដើមដម្លូង ផ្លែចេក

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាដើម ហៅថា **យាមកាលិក**, ភិក្ខុត្រូវទទួលទុកដាក់ឆាន់បាន ពីព្រឹមពេលព្រឹកដល់ថ្ងៃត្រង់, ទុកឱ្យកន្លងរាត្រី ឆាន់មិនបាន,

២- ទឹក ៨ ប្រការ ដែលគេធ្វើឱ្យសម្រេចដោយផ្លែឈើជាដើម គឺ *អម្ពបានំ* ទឹកផ្លែស្វាយ ១ *ជម្ពុបានំ* ទឹកផ្លែព្រីង ១ *ចោចបានំ* ទឹកផ្លែចេកមានគ្រាប់១ *មោច-បានំ* ទឹកផ្លែចេកឥតគ្រាប់ ១ *មធុកបានំ* ទឹកផ្លែស្រគំ ១ *មុទ្ទិកបានំ* ទឹកផ្លែចាន់ ១ *សាលុកបានំ* ទឹកមើមនៃផលជាតិ មានព្រលឹតក្រហមលំចង់ជាដើម ១ *ផារុសក-បានំ* ទឹកផ្លែមាក់ប្រាង ១. ។

មានទឹក ៨ យ៉ាងទៀតគឺ *កោសម្ពបានំ* ទឹកផ្លែសង្ស៊ែរ ១ *កោលបានំ* ទឹកផ្លែពុទ្រាតូច ១ *ពទរបានំ* ទឹកផ្លែពុទ្រាធំ ១ *យតបានំ* ទឹកធ្វើដោយទឹកដោះរាវ ឬ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទឹកដោះថ្លា ១ *តេលបានំ* ទឹកធ្វើដោយប្រេងមានប្រេងល្ង ជាដើម ១ *បយោបានំ* ទឹកធ្វើដោយទឹកដោះស្រស់ ១ *យាគុបានំ* ទឹកធ្វើដោយបបរ ១ រសបានំ ទឹកធ្វើដោយរសជាតិនៃវត្ថុមានបន្លែជាដើម ១ ។ **ទឹកបាន** ទាំងនេះ ជាភេសជ្ជៈ **យាមកាលិក**, ភិក្ខុឆាន់ក្នុងវេលាវិកាបាន តែទទួលទុកដាក់ឆាន់បានត្រឹម ១ ថ្ងៃ ១ យប់ ប៉ុណ្ណោះ យ៉ាងយូរ, បើទុកឱ្យហួសពីកាលកំណត់នេះ ហើយភិក្ខុយកមកឆាន់, ត្រូវអាបត្តិទុក្កដ ។

៣- ភេសជ្ជៈ ៥ យ៉ាង (មានទឹកដោះរាវជាដើម) និងថ្នាំដែលផ្សំដោយខ្លាញ់ គឺខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា ជាដើម, ភេសជ្ជនេះ ហៅថា **សត្តាហ-កាលិក**, ភិក្ខុត្រូវទទួលទុកដាក់ឆាន់បាន យ៉ាងយូរបំផុត

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្រឹម ៧ ថ្ងៃ, បើទុកឱ្យហួសពីកាលនេះ ហើយភិក្ខុយកមកឆាន់, ត្រូវអាបត្តិទុក្កដ ។

៤- ភេសជ្ជៈដែលត្រាំដោយទឹកមូត្រគោ និងថ្នាំ ដែលផ្សំដោយមើមឬឫស គឺមើមរមៀត, មើមខ្ញី, មើមលំពាន់, មើមប្រស់, មើមអាច់ផ្លឹស, មើមរំដេង, មើមស្មៅក្រវាំញញ្រ្ជូក ឫសស្បូវភ្លាំងជាដើម, ភេសជ្ជៈនេះ ហៅថា **យាវជីវិក**, ភិក្ខុទទួលទុកដាក់ឆាន់បាន ដរាបទល់នឹងភេសជ្ជៈនោះអស់ មិនមានកំណត់កាលឡើយ ។

ការធ្វើ **ទាន** ដូចបានរៀបរៀងទុកមកហើយខាងដើមនោះ ទោះទាយកធ្វើនឹងសមណៈក្នុងព្រះពុទ្ធសាសនា **ជាបាដិ-បុគ្គលិកទាន** ឬ **ជាសង្ឃគតាទក្ខិណាទាន** ជាដើមក្តី ធ្វើនឹងស្មូមយាចក ជាអ្នកក្រីក្រលំបាក អនាថា ឥតមានទីពឹង តែជាអ្នកទ្រទ្រង់សីល ៥ ជាដើមក្តី ឥតទ្រទ្រង់សីលធម៌ក្តី ឬក៏ធ្វើនឹងសត្វតិរច្ឆានក្តី ដែលនឹងកំណត់ឱ្យដឹងថា ជាទានមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ផលតិចច្រើន ឬខ្ពស់ទាបជាងគ្នាបាននោះ សប្បុរសគប្បីសង្កេតមើលសេចក្តី ក្នុង **ទានលក្ខណកថា** ដែលបានអធិប្បាយពន្យល់អំពីវិធីធ្វើទានរួចមកហើយនោះ ឱ្យបានចូលចិត្តជាក់លាក់ រួចចូរវិនិច្ឆ័យកំណត់យកទុកក្នុងចិត្តចំពោះខ្លួនចុះ ។

ឯអានិសង្សនៃទាននេះ នឹងមានសំដែងក្នុង **ទានានិសំសកថា** ជាសេចក្តីសង្ខេបដូចតទៅខាងក្រោយនេះ ។

ទានលក្ខណកថា ចប់ ដោយសង្ខេប ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ទាននិសំសកថា

*ទាន* មានដំណើរជាប់ទាក់ទងដោយវត្ថុខ្លះ ដោយចេតនាខ្លះ ដោយបុគ្គលអ្នកឱ្យខ្លះ បុគ្គលអ្នកទទួលខ្លះ តាមឈ្មោះផ្សេងៗ ពីគ្នា តែបើពោលតាមភូមិនៃបុគ្គល និងវត្ថុ មាន ៣ យ៉ាងគឺ បុគ្គលណា បរិភោគវត្ថុថោកទាប ដោយខ្លួនឯង លុះត្រូវការធ្វើទាន ក៏ចាត់ចែងឱ្យវត្ថុដ៏ថ្លៃថ្លាដល់បុគ្គលដទៃ, បុគ្គលនោះឈ្មោះថា **ទានបតិ** ឬ **ទានសា្វមី** ប្រែថា អ្នកមានទានជាម្ចាស់ គឺថា លើកទានឱ្យជាម្ចាស់របស់ខ្លួន ១, បុគ្គលណាបរិភោគវត្ថុបែបណា ដោយខ្លួនឯង លុះត្រូវការឱ្យទាន ដល់បុគ្គលដទៃ ក៏ឱ្យវត្ថុបែបនោះដែរ បុគ្គលនោះឈ្មោះថា **ទានសហាយៈ** ប្រែថា អ្នកមានទានជាសំឡាញ់ ១, បុគ្គលណាបរិភោគវត្ថុថ្លៃថ្លាដោយខ្លួនឯង លុះវេលាឱ្យទាន ក៏ត្រឡប់ជាយកវត្ថុថោកទាប ទៅឱ្យទានដល់បុគ្គលដទៃវិញ, បុគ្គលនោះឈ្មោះថា **ទានទាសៈ** ប្រែថា អ្នកមានទានជាខ្ញុំ ១ ។

ការបរិច្ចាគទាន ភូមិនៃបុគ្គលនិងវត្ថុ ដូចបានពោលមកនេះ រមែងបានអានិសង្ស តាមថ្នាក់ យ៉ាងខ្ពង់ខ្ពស់,

Websites: WatKhemaraRatanaram.org or WatKhmers.org

កណ្តាល ចោកទាប តាមលំដាប់នៃទាននោះៗ ។ ទាននេះ ចាត់ជាកល្យាណវត្ថុមួយដ៏ប្រសើរ រមែងមាននៅប្រចាំលោក, ជាករណីយកិច្ចរបស់សប្បុរសដោយពិត តែជាទំនាស់របស់មនុស្សកំណាញ់ ទាននេះ រាប់ថាជាបវេណីធម៌ របស់បុព្វបុរស ឬចាត់ជាបុញ្ញនិធិ ជាទីពឹងពំនាក់ របស់សត្វលោក ។ ទាន រមែងសម្រេចប្រយោជន៍ឃើញជាក់ច្បាស់ ទាំងផ្លូវលោក និងផ្លូវធម៌ដោយពិត ។

បុគ្គលអ្នកឱ្យទាន ឈ្មោះថា បានឱ្យអាយុ, ឱ្យពណ៌-សម្បុរ, ឱ្យសេចក្តីសុខ, ឱ្យកម្លាំង, ឱ្យសេចក្តីអង់អាច ដល់បុគ្គលដទៃ ។ ការឱ្យទាននេះ ឈ្មោះថា ជាអ្នកចងមិត្ត ឬប្រ-មូលកម្លាំងទុកដោយប្រពៃ ព្រោះថា មនុស្សក្នុងលោក រមែងមានកិច្ចរវល់ធម្មតា កាលបើកិច្ចការ ដែលត្រូវធ្វើកើតឡើង បុគ្គលអ្នកឥតមិត្តសំឡាញ់ រមែងបានសេចក្តីលំបាកដោយកិច្ចការនោះៗ ផ្ទាល់ខ្លួនឯង, កាលបើមានមិត្តសំឡាញ់ត្រឹមណា ឈ្មោះថា មានកម្លាំងច្រើនត្រឹមណោះ ។ ទាននេះ ចាត់ជាមិត្តសំឡាញ់ ឬជាកម្លាំងដ៏ប្រសើរ, ជាបច្ច័យជួយជូនដំណើរឱ្យ

Websites: WatKhemaraRatanaram.org or WatKhmers.org

បានសេចក្ដីសុខ សេចក្ដីចំរើនដ៏ធំទូលាយ តាំងអំពីលោកនេះ រហូតដល់លោកខាងមុខ រាងកាយទាំងមូល ត្រូវមានអវៈ-យវៈ គឺដៃជើងជាមិត្តសំឡាញ់ ឬជាកម្លាំង សម្រាប់ទទួលធុរៈបានដោយស្រួល យ៉ាងណាមិញ, បុគ្គលអ្នកមានសទ្ធា ត្រេកអរក្នុងការបរិច្ចាគទាន ក៏រមែងបានទាននោះឯង ជាមិត្ត ជាកម្លាំង របស់ខ្លួនយ៉ាងនោះដែរ ។ បុគ្គលមិនមានសទ្ធា ជាអ្នកប្រកបដោយសេចក្ដីកំណាញ់ ហៅថា បុគ្គលគ្មានមិត្តសំឡាញ់ ឬគ្មានកម្លាំង ដូចគ្នានឹងរាងកាយដែលកំបុតអវយវៈ គឺដៃជើង ។ ទាននេះប្រាកដជាមាន គុណានិសង្សច្រើនយ៉ាង តែបើពោលដោយរួបរួមចំពោះអានិសង្សនៃទាននេះ មាន ៥ យ៉ាងគឺ

១- *បិយោ ហោតិ មនាបោ* អ្នកឱ្យទានរមែងជាទីស្រឡាញ់ ពេញចិត្តនៃអ្នកផងច្រើនគ្នា ដែលនៅជិតខាង ឬនៅក្នុងទីឆ្ងាយ,

២- *សប្បុរិសា ភជន្តិ* ពួកសប្បុរស រមែងរាប់រក សង្គ្រោះនូវបុគ្គលដែលមានសទ្ធាធ្វើទាន ដោយការស្វែង

រកប្រយោជន៍ នឹងប្រាថ្នាចង់ឱ្យបុគ្គលអ្នកឱ្យទាននោះ បាន សេចក្តីសុខចម្រើគ្រប់ប្រការ,

៣- *កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ* កិត្តិសព្ទដ៏ពីរោះ រមែងខ្ចរខ្ចាយ សុះសាយទៅក្នុងទិសទាំងពួង ទាំងមនុស្សនិងទេវតា ក៏រមែងឱ្យសព្ទសាធុការ,

៤- *វិសារទោ ឧបសង្កមតិ* អ្នកឱ្យទាន ទោះ ចូលទៅកាន់ចំណោមបរិស័ទណាមួយ រមែងមានសេចក្តីក្លៀវ ក្លា អង់អាច មិនក្រអិមក្រអៀម,

៥- *សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ* អ្នកឱ្យ ទាន លុះបែកធ្លាយរាងកាយឃ្លាតចាកលោកនេះ ក៏ទៅកើត ឯសុគតិសួគ៌ទេវលោក លុះច្យុតចាកទេវលោក ដោយអំណាច ឧស្សន្នកុសលជាប់មក ក៏បានកើតមកក្នុងមនុស្សលោកនេះ ទៀត រមែងកើតក្នុងត្រកូលខ្ពស់ ដែលសម្បូណ៌ដោយភោគ សម្ប័ទ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**អានិសង្ស** ទាំង ៥ យ៉ាង ដូចពោលមកនេះ ចែកចេញជាពីរផ្នែកគឺ **អានិសង្ស** ៤ ខាងដើម ជា **សន្ទិដ្ឋិកផល** គឺ ផលដែលគួរឃើញជាក់ច្បាស់ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ, **អានិសង្ស** មួយខាងចុង ជា **សម្បរាយិកផល** គឺ ផលដែលត្រូវបានជួបប្រសព្វ ឃើញច្បាស់ក្នុងបរលោក ។ ពណ៌នាមកនេះ ជាអានិសង្ស នៃ **អាមិសទាន** ។

លំដាប់ពីនេះ សូមសម្តែងអំពី អានិសង្ស នៃ **ធម្មទាន** ដោយសង្ខេបតទៅទៀត ។

ការសំដែងធម៌ជាសាធារណៈ ដល់បុគ្គលដទៃក្តី ប្រៀនប្រដៅប្រាប់អំពីគុណទោសខុសត្រូវ ក្នុងផ្លូវលោកផ្លូវធម៌ ចំពោះមនុស្សម្នាក់ៗ ក្តី បង្ហាត់បង្រៀនធម៌អាថ៌ ចំពោះពួកគណៈសា-ធារណៈក្តី លោកហៅថា **ធម្មទាន** ទាំងអស់ ។ ធម្មកថិក (លោកអ្នកសម្តែងធម៌) សំដែងអាថ៌ ឈ្មោះថា ប្រគល់នូវចំណេះវិជ្ជាប្រាជ្ញាស្មារតីដ៏ធំទូលាយ ដល់បុគ្គលដទៃ, ដូចយ៉ាងបុគ្គលដែលបានទទួលអំណោយសេចក្តីសុខ ដោយភោគសម្ប័ទ ឬ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដោយឋានន្តរ គឺតំណែងយសស័ក្តិណាមួយ សុទ្ធតែបានមកអំពីការរៀនសូត្រស្តាប់ទាំងអស់ ឬថា មានការស្តាប់នេះឯងជាមូលហេតុ ។ ការសិក្សា ការត្រងត្រាប់ស្តាប់យកឧបាយ នេះរាប់ថាជាមេគំនិត ឬជាដើមប៉ូច នៃប្រយោជន៍ សេចក្តីល្អគ្រប់យ៉ាង, បុគ្គលដែលបានសម្រេចមគ្គផលនិព្វាន ជាគុណវិសេសដ៏ខ្ពស់បំផុត ព្រោះអាស្រ័យការស្តាប់នេះឯងជាបច្ច័យ ។

ចំណែកខាងបុគ្គល អ្នកប្រៀនប្រដៅធម៌ឈ្មោះថា ឱ្យទានព្រះនិព្វាន, សមដូចពុទ្ធភាសិតថា *អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ* បុគ្គលណា ប្រៀនប្រដៅធម៌, បុគ្គលនោះ ឈ្មោះថា ឱ្យព្រះនិព្វាន (ដល់អ្នកដទៃ) ។ *សព្វទានំ ធម្មទានំ ជិនាតិ* ធម្មទានរមែងឈ្នះអស់ ទានទាំងពួង ។ **ធម្មទាន** ជាទានមានផលដ៏ខ្ពង់ខ្ពស់ ឈ្នះ អាមិសទានទាំងអស់ ដោយហេតុថា ជាប្រធាន ឬថា ជាជីវិតនៃអាមិសទាន។ **ធម្មទាន** ជាអាយុនៃព្រះពុទ្ធសាសនា អាចធ្វើព្រះពុទ្ធសាសនាឱ្យមានពន្លឺរស្មីរុងរឿងដរាបមក ។ ការសំដែងធម៌ ដល់អ្នក

Websites: WatKhemaraRatanaram.org or WatKhmers.org

ដទៃ កាលបើអ្នកស្តាប់ ទទួលស្តាប់ដោយគោរព រមែង បានអានិសង្សដ៏ប្រសើរ, ទាំងធម្មកឋិកលោកអ្នកសំដែង ក៏ បានទទួលអានិសង្ស ដ៏ថ្លៃថ្លាច្រើនយ៉ាងមកវិញ, បើពោលដោយ រួបរួម អានិសង្សនៃ **ធម្មទាន** នេះ មាន ៥ ប្រការគឺ

១- *អត្ថប្បដិសំវេទ ធម្មប្បដិសំវេទី* លោក អ្នកសំដែង កាលបើសំដែងដោយឋិតថ្វង់តាមអង្គនៃធម្មកឋិក ចំពោះព្រះសទ្ធម្ម នឹងរឹងរឹតតែជាអ្នកយល់ច្បាស់ធ្លុះធ្លាយ ក្នុង អត្ថក្នុងធម៌ ក្រៃលេងឡើងទៅទៀត,

២- *បាមោជ្ជំ* សេចក្តីរីករាយក្នុងអត្ថក្នុងធម៌ រមែង កើតឡើង គឺធម្មទេសនានោះ ក៏ពីរោះចាប់ចិត្តខ្លួនឯង និងបុគ្គល អ្នកស្តាប់ តាមលំដាប់នៃធម៌ ដែលលើកឡើងសំដែង,

៣- *បីតិ* សេចក្តីត្រេកអរមានកម្លាំងឆ្អែតចិត្ត ក្នុងអត្ថ កងធម៌នោះ ៗ កើតឡើង,

Websites: WatKhemaraRatanaram.org or WatKhmers.org

៨- *បស្សទ្ធិ* រូបកាយនិងនាមកាយ របស់លោកអ្នកសំដែង និងអ្នកស្តាប់ ក៏ស្ងប់រម្ងាប់ចាកអកុសលធម៌ផ្សេងៗដរាបដល់ចិត្តសង្វេគ តក់ស្លុតក្នុងសង្ខារទាំងឡាយ

៩- *សមាធិ* ចិត្តរបស់លោក ដែលលកំពុងសំដែងធម៌ក៏តាំងមាំក្នុងការស្ងប់ស្ងាត់ចាកនីវរណៈ ។ **អានិសង្ស** ទាំង៥យ៉ាងនេះជា **សន្ទិដ្ឋិកផល** គឺផលដែលឃើញច្បាស់ក្នុងបច្ចុ-ប្បន្ននេះក៏មាន ជា **សម្បរាយិកផល** គឺផលដែលត្រូវមានជាប់តទៅក្នុងបរលោកក៏មាន ។

ពណ៌នាមកក្នុងទានានិសំសកថា ចប់ ដោយសង្ខេបតែប៉ុណ្ណោះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# សេចក្ដីស្រង់

របស់ក្រុមជំនុំប្រែព្រះត្រៃបិដក ដែលស្រង់ជូនកុង្សីយ៍សេនាបតី ដោយសេចក្ដីពិនិត្យត្រឹមត្រូវ តាមគម្ពីរវិន័យបិដក ។ ខ្ញុំស្រង់យកមករៀបរៀងក្នុងប៉ែកខាងចុងសៀវភៅនេះ ដើម្បីឱ្យអ្នកសិក្សាងាយយល់ ។

## *អំពីកន្លែងចីវរ*

**ចីវរបញ្ចខណ្ឌ** (ចីវរ ៥ ផ្ទាំង) មានកន្លែងតែ ១០ គត់ គឺកន្លែង ធំ ៥ ហៅតាមព្រះពុទ្ធដីកាថា **មណ្ឌលៈ** ហៅតាមអដ្ឋកថា ថា **មហាមណ្ឌលៈ** កន្លែងតូច ៥ ហៅតាមពុទ្ធដីកាថា **អឌ្ឍមណ្ឌលៈ** ហៅតាមអដ្ឋកថា ថា **ខុទ្ទកមណ្ឌលៈ** រួមជាកន្លែង ១០ គត់ ។

ក្នុងខណ្ឌគឺផ្ទាំងមួយៗ ត្រូវបែងជា ៣ ភាគ, យកពីរភាគធ្វើជាកន្លែងធំ ព្រោះហេតុនោះបានជាហៅ **មហាមណ្ឌលៈ**

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រែថា (កន្លែងធំ), យកមួយភាគធ្វើជាកន្លែងតូច ព្រោះហេតុនោះ បានជាហៅថា **អឌ្ឍមណ្ឌលះ** ប្រែថា “កន្លែងកន្លះភាគ ឬកន្លែងពាក់កណ្ដាលពីកន្លែងធំ” ឬហៅថា **ខុទ្ទក-មណ្ឌលះ** ប្រែថា កន្លែងតូច, ក៏បាន) ។

ក្នុងគម្ពីរយោជនាមហាវគ្គ ចីវរក្ខន្ធកៈ មានសេចក្ដីប្រាប់ដោយដាច់ខាតថា *បញ្ច មហាមណ្ឌលំ បញ្ច ខុទ្ទក-មណ្ឌលំ* កន្លែងធំ ៥ កន្លែងតូច ៥ រួមជា ១០ គត់ ។

**ចីវរបញ្ចខណ្ឌ** ត្រូវធ្វើឱ្យមានកន្លែងត្រឹមតែ ១០ គត់ ប៉ុណ្ណោះ ទើបត្រូវតាមគម្ពីរព្រះពុទ្ធសាសនា, ដូចគម្រូដែលគួរភ្ជាប់មកជាមួនេះ ។

បើទុកជាចីវរ ដែលមានផ្ទាំងច្រើនលើសពី ៥ ទៅក៏ដោយ, ក្នុងផ្ទាំងមួយ ៗ ត្រូវធ្វើឱ្យមានកន្លែងត្រឹមតែពីរៗ គឺកន្លែងធំ១ កន្លែងតូច១ ដូចគ្នានឹងចីវរបញ្ចខណ្ឌដែរ ។ **ចីវរសត្តខណ្ឌ** (ចីវរ ៧ ផ្ទាំង) មានកន្លែង ១៤ គឺកន្លែធំ ៧ តូច ៧ ។ **ចីវរនវខណ្ឌ** (ចីវរ ៩ ផ្ទាំង) មានកន្លែង ១៨ គឺកន្លែង ធំ ៩

Websites: WatKhemaraRatanaram.org or WatKhmers.org

តូច ៩ ។ **ចីវរឯកានសខណ្ឌ** (ចីវរ ១១ ផ្ទាំង) មានកន្សែង ២២ គឺកន្សែងធំ១១ តូច១១ ។ បែបចីវរដែលត្រឹមត្រូវតាមពុទ្ធានុញ្ញាតមានតែ ៤ យ៉ាងប៉ុណ្ណោះ ។

## *អំពីថ្មេរចីវរ*

ចីវរនិងស្បង់ទាំង ២ យ៉ាងនេះ ត្រូវដេរតែ ១ ជាន់គ្រប់អន្លើ, លើកលែងតែត្រង់អនុវាតជុំវិញ និងត្រង់កន្សែងឈ្មោះ **គីវេយ្យកៈ** និង **ជង្ឃេយ្យកៈ** ចេញ ដែលត្រូវឱ្យដេរប៉ះសាច់សំពត់ថែមជា ២ ជាន់ ឬ ៣ ជាន់ក៏បាន ដើម្បីឱ្យមាំជាប់បានយូរ ដ្បិតសាច់សំពត់ត្រង់កន្លែង ៣ អន្លើនេះ ឆាប់រេចណាស់ ។ មានបាលីបង្គាប់ឱ្យដេរថា *ឯកច្ចិយំ ឧត្តរាសង្គំ* ចីវរឱ្យដេរតែ ១ ជាន់, *ឯកច្ចិយំ អន្តរវាសកំ* ស្បង់ឱ្យដេរតែ ១ ជាន់ ។ ដោយហេតុនេះ បានជាខ្នង់ចីពរ និងខ្នង់ស្បង់ត្រូវដេរថ្មេរមូល បញ្ចៀសកុំឱ្យទៅជា ២ ជាន់, បើដេរថ្មេរប្រក់នឹងទៅជា ២ ជាន់ខ្លះ ត្រង់ខ្នង់ដែលប្រក់,ទៅជា ១ ជាន់ខ្លះ ត្រង់

សាច់សំពត់លាតក្រៅពីរខ្ទង់, ខុសអំពីពុទ្ធានុញ្ញាត ដែលថា **ឯកច្ចិយំ** “ឱ្យដេរតែ ១ ជាន់” ។

មួយយ៉ាងទៀត មានពុទ្ធានុញ្ញាតថា *ទិគុណំ សង្ឃាដឹ* “សង្ឃាដី ២ ជាន់” គឺ ២ ជាន់គ្រប់អន្លើ, លើកលែងតែត្រង់ **អនុវាត** និង **គីវេយ្យកៈ** និង **ជង្ឃេយ្យក**, ទាំង ៣ អន្លើនេះចេញ ដែលមានបង្គាប់ឱ្យដេរប៉ះ ថែមជា ២ ជាន់ក៏បាន ៣ ជាន់ក៏បាន លើសពីនេះទៅក៏បាន ដើម្បីឱ្យមាំត្រង់កន្លែងឯទៀត ។ ចីពរ ស្បង់ សង្ឃាដី ទាំង ៣ យ៉ាងនេះ បានជាមានឈ្មោះហៅខុសគ្នា, ព្រោះមានបែបផ្សេងៗ ពីគ្នា, បើប្រសិនជាដូចៗគ្នា តើចាំបាច់ឱ្យឈ្មោះផ្សេងគ្នាធ្វើអ្វី? ដូចជាសម្លៀកបំពាក់របស់គ្រហស្ថ ដែលមានឈ្មោះហៅ ផ្សេងៗ ពីគ្នា ដូច្នោះដែរ ។

## សម្រេចសេចក្តី

ក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានព្រមព្រៀងសម្រេចសេចក្តីថា **ចីពរបញ្ចខណ្ឌ**

Websites: WatKhemaraRatanaram.org or WatKhmers.org

មានកន្ទៀងត្រឹម ១០ គត់ គឺ កន្ទៀងធំ ៥ កន្ទៀង តូច ៥ ។ ខ្នង់ចីពរនិងខ្នង់ស្បង់ត្រូវដេរថ្មេមូល គឺដេរទុកសាច់សំពត់ ត្រង់កណ្ដាលខ្នង់តែ ១ ជាន់ៗ គ្រប់អន្លើ, កុំដេរខ្នង់ប្រក់ជា ២ ជាន់ឡើយ ។ ធ្វើចីវរបែបនេះ ទើបត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។

---

# ចីវរបញ្ចខណ្ឌបុះឈ្មោះអង្គទាំង ៩




Websites: WatKhemaraRatanaram.org or WatKhmers.org

# អង្គចីវរ

អង្គចីវរទាំង ៩ យ៉ាង ស្រង់រៀបរៀងតាមលំដាប់

១- *កុសិ* ប្រែថា "ចម្រៀកសំពត់វែង" នៅត្រង់អនុវាតវែង ៗ ជុំវិញនិងត្រង់ខ្នង់វែង ៗ ២- *អឌ្ឍកុសិ* ប្រែថា "ចម្រៀកសំពត់កន្លះភាគពីកុសិ គឺចម្រៀកសំពត់ខ្លី ៗ" នៅត្រង់ខ្នង់ខ្លី ៗ ៣- *មណ្ឌលៈ* ប្រែថា "កន្សែងធំ" នៅត្រង់ផ្ទាំងធំ ៗ (បើចីវរបញ្ចខណ្ឌ កន្សែងធំនេះ មាន ៥ ផ្ទាំង), ៤- *អឌ្ឍមណ្ឌល* ប្រែថា "កន្សែងកន្លះភាគពីកន្សែងធំ គឺកន្សែងតូច" នៅត្រង់ផ្ទាំងតូចៗ (បើចីវរបញ្ចខណ្ឌ កន្សែងតូចនេះមាន ៥ ផ្ទាំង) ៥- *វិវដ្ដៈ* ប្រែថា "ផ្ទាំងសំពត់បើកពេញ (កាលណាឃ្លុំ ឃើញច្បាស់ពីត្រង់ខាងលើខ្នង់)" អង្គនេះ នៅត្រង់ផ្ទាំងធំកណ្ដាល, ៦- អនុវិវដ្ដៈ ប្រែថា ផ្ទាំងសំពត់បើកបន្ទាប់ (កាលណាឃ្លុំ ឃើញតែ ១ ចំហៀង, អង្គ

Websites: WatKhemaraRatanaram.org or WatKhmers.org

នេះ នៅត្រង់ផ្ទាំង ២- អមវិវដ្ដៈ (មួយខាង,) *៧- គីវេយ្យកៈ* ប្រែថា "សំពត់ត្រូវរុំព័ទ្ធក (កាលណាឃ្លុំត្រូវរុំព័ទ្ធត្រង់ក)" អង្គនេះ នៅត្រង់ផ្ទាំងវិវដ្ដៈប៉ែកខាងលើ, *៨- ជង្ឃេយ្យកៈ* ប្រែថា "សំពត់ត្រូវគ្របលើស្មង កាលណាឃ្លុំ ត្រូវនៅត្រង់ខាងលើស្មង)" អង្គនេះ នៅត្រង់ផ្ទាំងអនុវិវដ្ដៈទាំង ២ ប៉ែកខាងក្រោម, *៩- ពាហន្តៈ* ប្រែថា "សំពត់ត្រូវគ្របកំភួនដៃ (កាលណាឃ្លុំ ត្រូវនៅត្រង់ខាងលើកំភួនដៃ)" អង្គនេះ នៅត្រង់អឌ្ឍមណ្ឌលៈនៃខណ្ឌ ២ ខាងក្រៅគេបំផុត ។ រួមត្រូវជាចីវរមានអង្គ ៩ ។ ចីវរមានអង្គ ៩ ដូច្នេះ ទើបត្រូវតាមពុទ្ធានុញ្ញាត ។ ចីវរទាំង ៣ គឺសង្ឃាដី, ចីពរ ស្បង់ ត្រូវធ្វើឱ្យប្រកបដោយអង្គ ៩ នេះដូចគ្នា វៀរលែងតែសំពត់ខាតធ្វើមិនគ្រាន់ ។១៚

Websites: WatKhemaraRatanaram.org or WatKhmers.org


ព្រះបាឡាត់ឃោសធាគ
ហែម_ចៀវ
(ជោតញ្ញាណោ)
អាចារ្យ
សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ
ប្រៀបរៀង
INSTITUT BOUDDHIQUE
ភ្នំពេញ
ព.ស. ២៥០៩